United Nations
Educational, Scientific and
Cultural Organization

Organisation
des Nations Unies
pour l'éducation,
la science et la culture

Organización
de las Naciones Unidas
para la Educación,
la Ciencia y la Cultura

Организация
Объединенных Наций по
вопросам образования,
науки и культуры

منظمة الأمم المتحدة
للتربيـة والعلم والثقافة

联合国教育、
科学及文化组织

CLT/CIH/MCO/2010/PI/144
Paris, 26 Février 2010
Original: English

Official Translation of the 1954 Hague Convention for the Protection
of Cultural Property in the Event of Armed Conflict

Submitted by Cambodia

Protection of Cultural Property in the Event of Armed Conflict

# អនុសញ្ញា ស្តីអំពី
# ការការពារសម្បត្តិវប្បធម៌
# ក្នុងគ្រាមានជំលោះប្រដាប់អាវុធ
# (អនុសញ្ញាក្រុងឡាអេ)
# ភ្ជាប់ជាមួយនិង បទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញា
# ព្រមទាំង ពិធីសាររបស់អនុសញ្ញា និងសេចក្តីសំរេចរបស់សន្និបាត *

## បុព្វកថា

អនុសញ្ញានេះគឺជាបច្ច័យបន្តមកពីអនុសញ្ញាទី ដែលមានឈ្មោះថា អនុសញ្ញាឆ្នាំ១៩០៧ ដែលចែងអំពីច្បាប់ និងទំលាប់នៃសង្គ្រាមនៅលើដែនដី ហើយដែលបានបង្កើតជាលើកទីមួយនូវទំរង់ដើមដំបូងបំផុតនៃការការពារជាអន្តរជាតិ ដល់សំណង់ធំៗទាំងឡាយដែលមានតំលៃខាងសិល្បៈ វិទ្យាសាស្ត្រ ក៏ដូចជាវិមានប្រវត្តិសាស្ត្រនានា។ អនុសញ្ញានេះបានចែងនូវមាត្រាបញ្ញត្តិទាំងឡាយ ស្តីអំពីការថែរក្សាចលនៈ និងអចលនវត្ថុដែលមានសារសំខាន់បំផុតចំពោះបេតិកភ័ណ្ឌវប្បធម៌របស់ប្រជាជាតិទាំងឡាយ ដោយពុំគិតពីប្រភពដើម ឬម្ចាស់កម្មសិទ្ធិ ហើយនិងធ្វើអោយកើតមាននូវសេចក្តីគោរពដល់សម្បត្តិដែលត្រូវតែគោរពដោយខានពុំបានទាំងនោះ ។

ការការពារសម្បត្តិទាំងនោះមានន័យថា រដ្ឋទាំងឡាយដែលនៅលើដែនដីខ្លួនមានសម្បត្តិវប្បធម៌តាំងនៅចាប់តាំងពីពេលដែលប្រទេសមានសន្តិភាពមកម្លេះ ត្រូវតែចាត់គ្រប់វិធានការចាំបាច់ដើម្បីការពារសម្បត្តិទាំងនោះ ។

ការគោរពដល់សម្បត្តិដែលត្រូវការពារ គឺជាកាតព្វកិច្ចដែលត្រូវតែបំពេញ ទាំងនៅលើដែនដីរបស់ខ្លួនផ្ទាល់ ទាំងនៅលើដែនដីរបស់ប្រទេសបដិបក្ខ នៅពេលណាដែលជំលោះប្រដាប់អាវុធកើតមានឡើង ។ ការគោរពយ៉ាងដូច្នោះដល់សម្បត្តិដែលត្រូវការពារ មានន័យថា សមាជិកទាំងអស់នៃអនុសញ្ញា យល់ព្រមបញ្ឈប់រាល់សកម្មភាពទាំងឡាយ ដែលអាចបណ្តាលអោយសម្បត្តិវប្បធម៌ធ្លាក់ទៅក្នុងភាពវិនាសអន្តរាយ និងបញ្ឈប់រាល់អំពើអមិត្តសំដៅប្រឆាំងដោយផ្ទាល់ទៅលើសម្បត្តិទាំងនោះ ។ លើសពីនោះទៀត គេត្រូវហាមឃាត់ និងប្រសិនបើចាំបាច់ គឺទប់ស្កាត់នូវរាល់អំពើលួចប្លន់ឬការប្រើប្រាស់សម្បត្តិវប្បធម៌ខុសគោលដៅ ។

មាត្រាបញ្ញត្តិមួយ បានតំរូវអោយមានការការពារ ជាពិសេសសំរាប់សម្បត្តិវប្បធម៌ ដែលមានសារៈប្រយោជន៍ សំខាន់ និងសំរាប់កន្លែងដែលសង់ជាជំរកការពារសម្បត្តិវប្បធម៌ទាំងនោះ ។

បទដ្ឋាននៃការអនុវត្តអនុសញ្ញា បានចែងនៅក្នុងបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញា ដែលតាមគំនិតផ្តួចផ្តើមរបស់លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ត្រូវបានគេយកទៅអនុវត្តជាលើកដំបូងនៅក្នុងអំឡុងឆ្នាំ១៩៦៧ នៃជំលោះនៅមជ្ឈឹមបូព៌ា ។

អនុសញ្ញាក៏ចែងផងដែរថា ប្រទេសចុះកិច្ចសន្យាទាំងអស់ យ៉ាងហោចណាស់ រៀងរាល់៤ឆ្នាំម្តងត្រូវផ្តល់ជូនលោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ នូវរបាយការណ៍មួយច្បាប់ស្តីអំពីបណ្តាវិធានការដែលកំពុងអនុវត្ត វិធានការដែលបានរៀបចំឡើង ឬដែលត្រៀមនឹងធ្វើសំដៅអនុវត្តអនុសញ្ញា និងបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញានេះ ។

អនុសញ្ញានេះមានអនុភាពគតិយុត្តិ ពីថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៥៦ ។

ពិធីសារ ត្រូវបានអនុម័តដោយសន្និសីទទីក្រុងឡាអេ នៅពេលព្រមគ្នាដែលគេអនុម័តអនុសញ្ញាឆ្នាំ១៩៥៤ ក្នុងនោះបានហាមប្រាមដល់ប្រទេសដែលជាភាគីចុះកិច្ចសន្យាទាំងអស់ មិនអោយនាំចេញសម្បត្តិវប្បធម៌ពីក្នុងដែនដីដែលខ្លួនបានចូលទៅកាន់កាប់ ។ លើសពីនេះទៅទៀត ប្រទេសទាំងអស់នោះត្រូវចាត់គ្រប់វិធានការចាំបាច់ ដើម្បីទប់ស្កាត់រាល់ការនាំចេញសម្បត្តិវប្បធម៌ ទោះជាប្រព្រឹត្តដោយបុគ្គលណាក៏ដោយ ។

ទោះបីជាបានចាត់វិធានការហើយក្តី តែបើសិនជាមានសម្បត្តិវប្បធម៌ណាមួយត្រូវបានគេនាំចេញពីក្នុងដែនដីដែលត្រូវបានភាគីម្ខាងទៀតចូលទៅកាន់កាប់ សម្បត្តិនោះត្រូវតែបញ្ជូនទៅអោយរដ្ឋអំណាចមានសមត្ថកិច្ចនៃដែនដីនោះវិញនៅពេលបញ្ចប់ជំលោះ ហើយការសងចំពោះអ្នកទិញ ឬជនជាម្ចាស់សុចរិតនៃសម្បត្តិនោះ នឹងត្រូវចំណាយទូទៅដោយប្រទេសដែលបានចូលទៅកាន់កាប់ទឹកដីនោះ កាលពីក្នុងអំឡុងពេលនៃវិវាទប្រដាប់អាវុធ ។ ពិធីសារបានចែងទៀតថា សម្បត្តិវប្បធម៌ដែលត្រូវបានគេបញ្ជូនចេញមកអំពីដែនដីដែលត្រូវគេចូលទៅកាន់កាប់នោះ មិនត្រូវប្រកាន់ទុកថាជាសំណងជួសជុលការបង់ខាតដោយសារសង្គ្រាមឡើយ ។

ពិធីសារ បានចូលជាធរមាននៅថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៥៦ ។

អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ

**អនុសញ្ញា**

# អនុសញ្ញាស្ដីពី
# ការការពារសម្បត្តិវប្បធម៌
# ក្នុងគ្រាមានជំលោះប្រដាប់អាវុធ

Convention for the Protection of Cultural Property in the Event of Armed Conflict

អនុម័តនៅទីក្រុងឡាអេ ថ្ងៃទី១៤ ឧសភា ១៩៥៤

ប្រទេសចុះកិច្ចសន្យាទាំងអស់

**ដោយទទួលស្គាល់ថា** សម្បត្តិវប្បធម៌បានទទួលរងការខូចខាតដ៏ធ្ងន់ធ្ងរក្នុងអំឡុងនៃជំលោះប្រដាប់អាវុធនាពេលថ្មីៗនេះ និងដោយសារមូលហេតុនៃការអភិវឌ្ឍបច្ចេកទេសនៃការធ្វើសង្គ្រាម សម្បត្តិវប្បធម៌កំពុងស្ថិតនៅក្នុងគ្រោះថ្នាក់នៃការបំផ្លិចបំផ្លាញដែលកាន់តែធ្ងន់ធ្ងរទៅៗ ។

**ដោយយល់ឃើញថា** ការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ ទោះជារបស់ជនជាតិណាមួយក៏ដោយ គឺមានន័យថា ជាការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌របស់មនុស្សជាតិទាំងមូល ពីព្រោះជាតិនីមួយៗបានផ្ដល់នូវវិភាគទានរបស់ខ្លួនដល់វប្បធម៌របស់ពិភពលោក ។

**ដោយពិចារណាឃើញថា** ការថែរក្សាមរតវប្បធម៌មានសារសំខាន់យ៉ាងខ្លាំងសំរាប់ប្រជាជាតិទាំងអស់ក្នុងពិភពលោក ហើយគឺជាការចាំបាច់ណាស់ដែលមរតកនេះគប្បីត្រូវបានទទួលការការពារជាអន្តរជាតិ ។

**ដោយអនុវត្តទៅតាម** គោលការណ៍នៃការការពារសម្បត្តិវប្បធម៌ក្នុងពេលមានសង្គ្រាម ដូចមានចែងនៅក្នុងអនុសញ្ញាក្រុងឡាអេ ឆ្នាំ១៨៩៩ និងឆ្នាំ១៩០៧ និងនៅក្នុងកតិកាសញ្ញាក្រុងវ៉ាស៊ីនតោន ចុះថ្ងៃទី១៥ មេសា ១៩៣៥ ។

**ដោយយល់ឃើញថា** ការការពារបែបនេះពុំអាចមានប្រសិទ្ធភាពបានឡើយ ដរាបណាវិធានការទាំងក៏រិតជាតិ និងអន្តរជាតិមិនត្រូវបានបង្កើតឡើងនៅក្នុងពេលដែលប្រទេសមានសន្តិភាពទេនោះ ។

**ដោយម្ដេថ្វា** អនុវត្តគ្រប់វិធានការដែលអាចធ្វើទៅបានដើម្បីការពារសម្បត្តិវប្បធម៌ ។

បានព្រមព្រៀងលើប្រការទាំងឡាយដូចតទៅ:

## ជំពូកទី១
## បទបញ្ញត្តិទូទៅស្ដីពីកិច្ចការពារ
### មាត្រា១: និយមន័យនៃសម្បត្តិវប្បធម៌

សំរាប់គោលបំណងនៃអនុសញ្ញានេះពាក្យថា *សម្បត្តិវប្បធម៌* ដោយពុំគិតពីប្រភពដើម ឬម្ចាស់កម្មសិទ្ធិ រួមមានៈ

ក- ចលនៈ ឬអចលនសម្បត្តិដែលមានសារសំខាន់ចំពោះកេរ្តិ៍មរតក វប្បធម៌របស់ប្រជាជាតិនីមួយៗដូចជា វិមានដែលមានចរិតជាស្ថាបត្យកម្ម សិល្បៈ ឬប្រវត្តិសាស្ត្រ ទោះជាមាន ឬគ្មានលក្ខណៈសាសនា រមណីយដ្ឋានបុរាណវត្ថុ ក្រុមអគារដែលមានសារសំខាន់ផ្នែកប្រវត្តិសាស្ត្រ ឬសិល្បៈ សំណេរដៃនៃស្នាដៃនិពន្ធ សៀវភៅ និងវត្ថុដទៃទៀតដែលមានសារសំខាន់ផ្នែកសិល្បៈ ប្រវត្តិសាស្ត្រ ឬបូរាណវិទ្យា ក៏ដូចជាសមុច្ច័យវិទ្យាសាស្ត្រ និងសៀវភៅផ្សេងៗទៀត ឬប័ណ្ណសារសំខាន់ៗ ឬវត្ថុចំលងឡើងវិញនៃវត្ថុវប្បធម៌ដែលរៀបរៀងខាងលើ ។

ខ- អគារទាំងឡាយណាដែលគេប្រើប្រាស់សំរាប់ថែរក្សា ឬដាក់តាំងបង្ហាញចលនសម្បត្តិវប្បធម៌ ដែលរៀបរាប់នៅក្នុងអនុកថាខ័ណ្ឌ ក ដូចជា សារមន្ទីរ បណ្ណាល័យធំៗ និងប័ណ្ណសារដ្ឋានទាំងឡាយ ព្រមទាំងទីតាំងនានា ដែលក្នុងពេលមានវិវាទប្រដាប់អាវុធបានប្រើប្រាស់ជាជំរកសំរាប់ចលនសម្បត្តិវប្បធម៌ដូចមានរៀបរាប់នៅក្នុងអនុកថាខ័ណ្ឌ ក ។

គ- មជ្ឈមណ្ឌលទាំងឡាយណា ដែលសំបូរទៅដោយសម្បត្តិវប្បធម៌ដូចមានរៀបរាប់កំណត់នៅក្នុងអនុកថាខ័ណ្ឌ ក និងខ ទីនោះត្រូវសំគាល់ថាជា "មជ្ឈមណ្ឌលដែលមានមរតកវប្បធម៌តាំងនៅ" ។

## មាត្រា២ៈ ការការពារសម្បត្តិវប្បធម៌

សំរាប់គោលបំណងនៃអនុសញ្ញានេះ ការការពារសម្បត្តិវប្បធម៌ រួមមានការថែរក្សា និងការគោរពដល់សម្បត្តិវប្បធម៌ទាំងនោះ ។

## មាត្រា៣ៈ ការថែរក្សាសម្បត្តិវប្បធម៌

ប្រទេសចុះកិច្ចសន្យាទាំងអស់ត្រូវដាក់ផែនការត្រៀមជាស្រេច ក្នុងពេលប្រទេសមានសន្តិភាព អំពីការងារការពារសម្បត្តិវប្បធម៌ដែលស្ថិតនៅក្នុងដែនដីរបស់ខ្លួន បង្ការចំពោះផលប៉ះពាល់ដែលអាចប្រមាណទុកជាមុនបាន កាលណាបើកើតមានអធិករណ៍ប្រដាប់អាវុធ ដោយអនុវត្តនូវគ្រប់វិធានការដែលខ្លួនយល់ថាសមស្រប ។

## មាត្រា៤ៈ ការគោរពសម្បត្តិវប្បធម៌

១- ប្រទេសចុះកិច្ចសន្យាទាំងអស់ត្រូវគោរពដល់សម្បត្តិវប្បធម៌ដែលស្ថិតនៅក្នុងដែនដីខ្លួនផ្ទាល់ ក៏ដូចជានៅក្នុងដែនដីរបស់ប្រទេសចុះកិច្ចសន្យាដទៃទៀតដែរ ដោយបញ្ឈប់រាល់ការប្រើប្រាស់សម្បត្តិវប្បធម៌

ក៏ដូចជាតំបន់ដែលស្ថិតនៅជិតជុំវិញតំបន់សម្បត្តិវប្បធម៌ បញ្ឈប់ការប្រើប្រាស់រាល់សំភារៈ ឧបករណ៍ទាំងឡាយណាដែលគេប្រើប្រាស់សំរាប់រក្សាការពារសម្បត្តិវប្បធម៌ ដែលការប្រើប្រាស់ទាំងនោះអាចបណ្តាលអោយខូចខាត ឬបាត់បង់សម្បត្តិវប្បធម៌ នៅក្នុងពេលមានវិវាទប្រដាប់អាវុធ និងបញ្ឈប់នូវរាល់សកម្មភាពអមិត្តដែលធ្វើឡើងសំដៅប្រឆាំងដោយផ្ទាល់ទៅលើសម្បត្តិវប្បធម៌ ។

២- កាតព្វកិច្ចដែលចែងនៅក្នុងកថាខ័ណ្ឌទី១នៃមាត្រានេះ អាចត្រូវលើកលែងតែនៅក្នុងករណីណាដែលកំរិតចាំបាច់នៃការងារយោធាទាមទារដាច់ខាតដោយខានពុំបានតែប៉ុណ្ណោះ ។

៣- ប្រទេសចុះកិច្ចសន្យាទាំងអស់ត្រូវហាមឃាត់ ទប់ស្កាត់ និងប្រសិនបើចាំបាច់ បញ្ឈប់គ្រប់រូបភាពនៃអំពើលួចប្លន់ ការយកទៅប្រើប្រាស់ជាសម្បត្តិផ្ទាល់ខ្លួនដោយខុសច្បាប់ និងរាល់អំពើបំផ្លិចបំផ្លាញដោយផ្ទាល់ទៅលើសម្បត្តិវប្បធម៌ ។ បណ្តាប្រទេសចុះកិច្ចសន្យាទាំងអស់ក៏ត្រូវតែបញ្ឈប់នូវរាល់សកម្មភាពប៉ុនប៉ងចង់បានចលនសម្បត្តិវប្បធម៌ ដែលស្ថិតនៅលើទឹកដីរបស់ប្រទេសចុះកិច្ចសន្យាមួយទៀតនោះផងដែរ ។

៤- ប្រទេសចុះកិច្ចសន្យាទាំងអស់នឹងមិនធ្វើរាល់សកម្មភាពក្នុងរបៀបជាអំពើវាយសងសឹក សំដៅទៅលើសម្បត្តិវប្បធម៌ឡើយ ។

៥- គ្មានប្រទេសចុះកិច្ចសន្យាណាមួយអាចរំលោភបំពានលើកាតព្វកិច្ចដែលខ្លួនទទួលខុសត្រូវ ដូចដែលបានចែងនៅក្នុងមាត្រានេះ ទៅលើប្រទេសចុះកិច្ចសន្យាមួយផ្សេងទៀត ដោយសំអាងមូលហេតុថាប្រទេសចុះកិច្ចសន្យាមួយទៀតនោះពុំបានអនុវត្តវិធានការរក្សាការពារ ដូចមានចែងក្នុងមាត្រា៣នោះបានឡើយ ។

## មាត្រា៥: ការចូលកាន់កាប់ទឹកដី

១- ប្រទេសចុះកិច្ចសន្យាណាមួយដែលបានចូលកាន់កាប់ដែនដីមួយចំណែក ឬទាំងមូលរបស់ប្រទេសចុះកិច្ចសន្យាមួយផ្សេងទៀតត្រូវគាំទ្រអោយបានខ្លាំងក្លាតាមដែលអាចធ្វើទៅបាន ដល់រដ្ឋអំណាចជាតិមានសមត្ថកិច្ចរបស់ប្រទេសដែលត្រូវបានប្រទេសខ្លួនចូលទៅកាន់កាប់នោះ នៅក្នុងការថែរក្សា និងការពារសម្បត្តិវប្បធម៌ ។

២- ប្រសិនបើគេយល់ថាមានការចាំបាច់ ក្នុងការចាត់វិធានការថែរក្សាសម្បត្តិវប្បធម៌នៅក្នុងដែនដីដែលគេចូលទៅកាន់កាប់ ហើយដោយហេតុថាសម្បត្តិទាំងនោះបានខូចខាតដោយសារប្រតិបត្តិការសឹក និងប្រសិនបើរដ្ឋអំណាចជាតិមានសមត្ថកិច្ចពុំមានលទ្ធភាពអនុវត្តវិធានការទាំងនេះទេនោះ ប្រទេសដែល

ចូលទៅកាន់កាប់ដែនដីនោះត្រូវតែផ្តល់អោយកាន់តែច្រើន តាមដែលអាចធ្វើទៅបាន នូវវាលវិធានការដ៏ចាំបាច់បំផុតក្នុងការរក្សាការពារសម្បត្តិវប្បធម៌ ដោយសហការយ៉ាងជិតស្និតបំផុតជាមួយរដ្ឋអំណាចនៅទីនោះ ។

៣- ប្រទេសចុះកិច្ចសន្យាណាក៏ដោយ ដែលរដ្ឋាភិបាលរបស់ខ្លួនត្រូវបានសមាជិកនៃចលនាប្រឆាំងចាត់ទុកជារដ្ឋាភិបាលស្របច្បាប់ ប្រសិនបើអាច ត្រូវតែទាក់ទាញការយកចិត្តទុកដាក់របស់ក្រុមប្រឆាំងនោះអោយអនុវត្តកាតព្វកិច្ច ស្របតាមមាត្រាបញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងអនុសញ្ញានេះ នៅត្រង់មាត្រាទាំងឡាយណាដែលមានចែងអំពីការគោរពសម្បត្តិវប្បធម៌ ។

## មាត្រា៦: កំណត់ចំណាំដោយឡែកនៅលើសម្បត្តិវប្បធម៌

ដោយយោលទៅតាមប្រការទាំងឡាយដែលមានចែងនៅក្នុងមាត្រា១៦ សម្បត្តិវប្បធម៌ត្រូវមានសញ្ញាសំគាល់ដោយឡែកដើម្បីសំរួលអោយងាយចំណាំ ។

## មាត្រា៧: វិធានការយោធា

១- ប្រទេសចុះកិច្ចសន្យាទាំងអស់យល់ព្រម ក្នុងពេលមានសន្តិភាព បញ្ចូលទៅក្នុងច្បាប់ ឬវិន័យសំរាប់យោធា នូវមាត្រាបញ្ញត្តិទាំងនេះដែលអាចធានាដល់ការអនុវត្តអនុសញ្ញានេះ និងយល់ព្រមជួយជំរុញនៅក្នុងជួរកងកំលាំងប្រដាប់អាវុធអោយមានស្មារតីគោរពវប្បធម៌ និងសម្បត្តិវប្បធម៌របស់ប្រជាជាតិផងទាំងពួង ។

២- ប្រទេសចុះកិច្ចសន្យាទាំងអស់យល់ព្រមគ្រោង ឬបង្កើត ក្នុងពេលមានសន្តិភាព នៅក្នុងកងកំលាំងប្រដាប់អាវុធរបស់ខ្លួន នូវអង្គការសេវាកម្ម ឬបុគ្គលិកឯកទេស ដើម្បីថែរក្សា គោរពដល់សម្បត្តិវប្បធម៌ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយរដ្ឋអំណាចស៊ីវិល ដែលទទួលខុសត្រូវខាងកិច្ចការការពារសម្បត្តិវប្បធម៌ ។

# ជំពូកទី២

# ការការពារពិសេស

## មាត្រា៨: ការផ្តល់សេចក្តីអនុញ្ញាតិអោយមានការការពារពិសេស

១- គេអាចដាក់អោយស្ថិតនៅក្រោមការការពារពិសេស នូវទីកំណត់ទាំងឡាយណាដែលគេមានបំណងប្រើប្រាស់ជាជំរកការពារចលនសម្បត្តិវប្បធម៌នៅក្នុងគ្រាមានអធិករណ៍ប្រដាប់អាវុធ ជាមជ្ឈមណ្ឌល

ដែលមានកេរ្តិ៍ដំណែលវប្បធម៌ និងអចលនសម្បត្តិវប្បធម៌ដទៃទៀតដែលមានសារសំខាន់អោយតែទីតាំងទាំងនោះ:

ក- ស្ថិតនៅឆ្ងាយល្មមពីមជ្ឈមណ្ឌលឧស្សាហកម្មធំៗ ឬឆ្ងាយពីគោលដៅសំខាន់ៗផ្នែកយោធា ដែលជាចំនុចអាចទទួលរងការខូចខាត មានជាអាទិ៍ អាកាសយានដ្ឋាន ស្ថានីយ៍ផ្សាយពត៌មាន អគារដែលទាក់ទិនដល់ការងារការពារជាតិ កំពង់ផែ ឬស្ថានីយ៍រថភ្លើង ដែលមានសារសំខាន់ ក៏ដូចជាផ្លូវគមនាគមន៍សំខាន់ៗដទៃទៀត។

ខ- សុទ្ធតែពុំត្រូវបានប្រើប្រាស់សំរាប់គោលដៅយោធា។

២- ទីជំរកការពារចលនសម្បត្តិវប្បធម៌ អាចត្រូវគេដាក់អោយស្ថិតនៅក្រោមការការពារពិសេស ទោះស្ថិតនៅទីកន្លែងណាក៏ដោយ ប្រសិនបើទីជំរកទាំងនោះត្រូវបានគេសាងសង់ឡើងនៅលើទីតាំងដែលមានស្ថានភាពដូចបានរៀបរាប់ពីខាងលើ និងនៅគ្រប់ករណីយភាព ទីជំរកទាំងនោះនឹងពុំត្រូវបានគេធ្វើអោយខូចខាតដោយអាវុធគ្រាប់បែកឡើយ។

៣- មជ្ឈមណ្ឌលដែលមានមរតកវប្បធម៌ នឹងត្រូវចាត់ទុកថាត្រូវបានគេប្រើប្រាស់សំរាប់គោលដៅយោធា គឺនៅរាល់ពេលណាដែលមជ្ឈមណ្ឌលទាំងនោះត្រូវគេប្រើប្រាស់សំរាប់ការធ្វើសកម្មភាព ចុះឡើងរបស់បុគ្គលិក ឬសំភារៈយោធា ទោះបីគ្រាន់តែជាការផ្លាស់ប្តូរទីកន្លែង ឬការឈប់សំចតបណ្តោះអាសន្នក្តី។ ស្ថិតក្នុងន័យដូចគ្នានេះដែរ គឺនៅរាល់ពេលដែលមានសកម្មភាពទាក់ទិនដោយផ្ទាល់ជាមួយប្រតិបត្តិការសឹក ការបោះទីតាំងនៃបុគ្គលិកយោធា ឬការផលិតសំភារៈសឹក ត្រូវបានគេអនុវត្តឡើងនៅក្នុងមជ្ឈមណ្ឌល។

៤- ការការពារសម្បត្តិវប្បធម៌ដូចបានពណ៌នាកំណត់នៅក្នុងកថាខ័ណ្ឌទី១ខាងលើ ដែលអនុវត្តដោយឆ្មាំប្រដាប់អាវុធដែលត្រូវបានគេផ្តល់សិទ្ធិអំណាចពិសេសអោយធ្វើការងារនេះ ឬវត្តមានរបស់កងកំលាំងនគរបាលនៅតាមទីជិតខាងនៃតំបន់សម្បត្តិវប្បធម៌ទាំងនោះ ដែលមានភារកិច្ចទទួលខុសត្រូវជាប្រចាំដើម្បីថែរក្សាសណ្តាប់ធ្នាប់សាធារណៈ ពុំត្រូវចាត់ទុកថាជាការប្រើប្រាស់សំរាប់គោលដៅយោធាឡើយ។

៥- ប្រសិនបើសម្បត្តិវប្បធម៌ណាមួយ ដូចបានពណ៌នាកំណត់នៅក្នុងកថាខ័ណ្ឌទី១នៃមាត្រានេះស្ថិតនៅក្បែរគោលដៅយោធាសំខាន់ៗដូចបានបញ្ជាក់នៅក្នុងកថាខ័ណ្ឌទី១ដដែលនេះ គេអាចដាក់សម្បត្តិវប្បធម៌ទាំងនោះអោយស្ថិតនៅក្រោមការការពារពិសេស បើសិនជាប្រទេសចុះកិច្ចសន្យាដែលសំណូមពរអោយមានការការពារបែបនេះយល់ព្រម ក្នុងពេលកើតមានជំលោះប្រដាប់អាវុធ ពុំប្រើប្រាស់គោលដៅទាំង

នោះ និងជាពិសេសគឺ កំពង់ផែ អាកាសយានដ្ឋាន ឬស្ថានីយ៍រថភ្លើង ត្រូវតែបញ្ចៀសការធ្វើចរាចរចេញពីទីនោះ។ ក្នុងករណីនេះ ការបង្វែរទាំងអស់នោះ គប្បីត្រូវរៀបចំត្រៀមធ្វើឡើងតាំងតែពីពេលប្រទេសមានសន្តិភាព។

៦- គេអាចអនុញ្ញាតិអោយមានការការពារពិសេស ចំពោះសម្បត្តិវប្បធម៌ទាំងឡាយណាដែលមានឈ្មោះនៅក្នុង "បញ្ជីអន្តរជាតិនៃសម្បត្តិវប្បធម៌ដែលដាក់អោយស្ថិតនៅក្រោមការការពារពិសេស"។ ការបញ្ចូលទៅក្នុងបញ្ជីនឹងត្រូវធ្វើឡើង ដោយអនុលោមទៅតាមមាត្រាបញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងអនុសញ្ញានេះ និងនៅក្នុងល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញានេះ។

## មាត្រា៩: អភ័យឯកសិទ្ធិនៃសម្បត្តិវប្បធម៌ដែលដាក់អោយស្ថិតនៅក្រោមការការពារពិសេស

ប្រទេសចុះកិច្ចសន្យាទាំងអស់ យល់ព្រមធានាដល់អភ័យឯកសិទ្ធិនៃសម្បត្តិវប្បធម៌ដែលដាក់អោយស្ថិតនៅក្រោមការការពារពិសេស ដោយបញ្ឈប់ ចាប់តាំងពីពេលបញ្ចូលទៅក្នុងបញ្ជីអន្តរជាតិ នូវរាល់សកម្មភាពទាំងឡាយដែលប្រឆាំងនឹងសម្បត្តិវប្បធម៌ទាំងនោះ ហើយលើកលែងតែក្នុងករណីដែលមានចែងក្នុងកថាខ័ណ្ឌទី៥ នៃមាត្រា៨ បញ្ឈប់រាល់ការប្រើប្រាស់សម្បត្តិវប្បធម៌ ឬក៏តំបន់ជិតខាងនៃសម្បត្តិវប្បធម៌ទាំងនោះដើម្បីបំរើតំរូវការយោធា។

## មាត្រា១០: ការសំគាល់ និងការត្រួតពិនិត្យ

ក្នុងកំឡុងពេលកើតមានអធិករណ៍ប្រដាប់អាវុធ សម្បត្តិវប្បធម៌ដែលដាក់អោយស្ថិតនៅក្រោមការការពារពិសេស នឹងត្រូវបានដាក់សញ្ញាជាចំណាំដែលនឹងមានអធិប្បាយនៅក្នុងមាត្រា១៦ ហើយនឹងបើកចំហចំពោះការត្រួតពិនិត្យជាអន្តរជាតិ ដូចសេចក្តីមានចែងនៅក្នុងបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញានេះ។

## មាត្រា១១: ការលុបចោលអភ័យឯកសិទ្ធិ

១- ប្រសិនបើប្រទេសមួយក្នុងចំណោមប្រទេសចុះកិច្ចសន្យា ល្មើសទៅនឹងបញ្ញត្តិដែលចែងអំពីការគោរពចំពោះសម្បត្តិវប្បធម៌ដែលដាក់អោយស្ថិតនៅក្រោមការការពារពិសេស ដោយរំលោភទៅលើកាតព្វកិច្ចដែលមានចែងនៅក្នុងមាត្រា៩ ហើយក្នុងករណីដែលអំពើរំលោភចេះតែបន្ត ប្រទេសបដិបក្ខមួយទៀតនឹងត្រូវលើកលែងចេញពីកាតព្វកិច្ចក្នុងការធានាដល់អភ័យឯកសិទ្ធិនៃសម្បត្តិវប្បធម៌ដែលដាក់

ទិន។ លើសពីនេះទៀត ពេលណាដែលអាចធ្វើបាន ភាគីខាងក្រោយនេះ នឹងធ្វើសំណូមពរមុន អោយបញ្ឈប់អំពើរំលោភទាំងនោះ ក្នុងរយៈពេលសមស្រប ។

២- ក្រៅពីករណីដែលចែងនៅក្នុងកថាខ័ណ្ឌទី១ នៃមាត្រានេះ អភ័យឯកសិទ្ធិនឹងត្រូវគេលុបចេញពីសម្បត្តិវប្បធម៌ស្ថិតក្រោមការការពារពិសេស តែក្នុងករណីពិសេសចាំបាច់ខានពុំបានខាងវិស័យយោធា និងសំរាប់រយៈពេលដែលការចាំបាច់នេះចេះតែបន្តទៅទៀត ។ ការចាំបាច់នេះអាចស្នើឡើងតែដោយនាយទាហានដែលបញ្ជាអង្គភាពមួយមានទំហំប្រហាក់ប្រហែលនឹងកងពល ឬធំជាងនេះ។ ពេលណាដែលកាលៈទេសៈអនុញ្ញាត និងក្នុងកំឡុងពេលសមរម្យទុកជាមុន ប្រទេសបដិបក្ខ នឹងត្រូវបានគេផ្តល់ពត៌មានស្តីពីការលុបចោលអភ័យឯកសិទ្ធិ ។

៣- ប្រទេសដែលលុបចោលអភ័យឯកសិទ្ធិ យ៉ាងឆាប់បំផុតតាមដែលអាចធ្វើបាន ត្រូវផ្តល់ពត៌មានដល់លោកប្រធានអគ្គស្នងការទទួលបន្ទុកការងារសម្បត្តិវប្បធម៌ ដូចសេចក្តីដែលមានអធិប្បាយនៅក្នុងបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញានេះ ជាលាយលក្ខណ៍អក្សរ ដោយមានការបញ្ជាក់ពីមូលហេតុផង ។

## ជំពូកទី៣

## ការដឹកជញ្ជូនសម្បត្តិវប្បធម៌

### មាត្រា១២: ការដឹកជញ្ជូនក្រោមការការពារពិសេស

១- ការដឹកជញ្ជូនដែលទាក់ទិនដល់ការផ្លាស់ប្តូរទីកន្លែងសម្បត្តិវប្បធម៌ ទាំងនៅក្នុងរង្វង់ដែនដីណាមួយ ឬចេញពីដែនដីមួយចូលទៅកាន់ដែនដីមួយផ្សេងទៀត តាមសំណូមពររបស់ប្រទេសចុះកិច្ចសន្យាដែលទាក់ទិន អាចធ្វើឡើងក្រោមការការពារពិសេស ស្របទៅតាមល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញានេះ ។

២- ការដឹកជញ្ជូនក្រោមការការពារពិសេសនឹងធ្វើឡើងក្រោមការត្រួតពិនិត្យជាអន្តរជាតិ ដូចមានអធិប្បាយនៅក្នុងបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញានេះ ហើយនឹងមានបង្ហាញនូវសញ្ញាសំគាល់ពិសេស ដូចមានអធិប្បាយកំណត់នៅក្នុងមាត្រា១៦ ។

៣- ប្រទេសចុះកិច្ចសន្យាទាំងអស់ ត្រូវបញ្ឈប់រាល់សកម្មភាពអមិត្តសំដៅប្រឆាំងនឹងការដឹកជញ្ជូនសម្បត្តិវប្បធម៌ដែលដាក់អោយស្ថិតនៅក្រោមការការពារពិសេស ។

### មាត្រា១៣: ការដឹកជញ្ជូនក្នុងករណីបន្ទាន់

១- បើប្រទេសចុះកិច្ចសន្យាមួយយល់ឃើញថា សន្តិសុខរបស់សម្បត្តិវប្បធម៌ណាមួយទាមទារអោយមានការផ្លាស់ប្តូរទីកន្លែងវត្ថុនោះទៅកន្លែងដទៃ ហើយបញ្ហានោះជាការងារបន្ទាន់ដែលពុំអាចអោយគេអនុវត្តតាមកម្មវិធីដែលមានចែងនៅក្នុងមាត្រា១២ បាន ជាពិសេសគឺនៅគ្រាចាប់ផ្តើមដំបូងនៃវិវាទប្រដាប់អាវុធ ការដឹកជញ្ជូនសម្បត្តិទាំងនោះនឹងត្រូវបង្ហាញដោយផ្លាកសញ្ញាសំគាល់ពិសេស ដូចមានអធិប្បាយកំនត់នៅក្នុងមាត្រា១៦ អោយតែល័ក្ខខ័ណ្ឌដែលពាក្យសុំអោយមានអភ័យឯកសិទ្ធិដែលបាននិយាយយោងនៅមាត្រា១២ ពុំទាន់ត្រូវបានគេធ្វើ និងបដិសេធទេនោះ ។ ការផ្តល់ពត៌មានស្តីពីការដឹកជញ្ជូនសម្បត្តិវប្បធម៌ គប្បីប្រកាសអោយដឹងជាមុនតាមដែលអាចធ្វើបាន ដល់ទៅភាគីបដិបក្ខ ។ លើសពីនេះទៀត ការដឹកជញ្ជូនសម្បត្តិវប្បធម៌ទៅកាន់ដែនដីនៃប្រទេសមួយផ្សេងទៀត មិនអាចបង្ហាញសញ្ញាសំគាល់បានទេ បើសិនជាសម្បត្តិវប្បធម៌ទាំងនោះពុំទាន់ត្រូវបានគេផ្តល់អភ័យឯកសិទ្ធិអោយទេនោះ ។

២- ប្រទេសចុះកិច្ចសន្យាទាំងអស់ តាមដែលអាចធ្វើទៅបាន គប្បីប្រកាន់យកការបង្ការទុកជាចាំបាច់ទាំងឡាយសំរាប់ធានាដល់ការងារដឹកជញ្ជូន ដូចមានចែងនៅក្នុងកថាខ័ណ្ឌទី១នៃមាត្រានេះ និងដាក់បង្ហាញផ្លាកសញ្ញាសំគាល់ ដើម្បីប្រឆាំងទល់នឹងរាល់សកម្មភាពអមិត្តដែលត្រូវបានគេធ្វើឡើងសំដៅទៅលើការដឹកជញ្ជូនទាំងនោះ ។

## មាត្រា១៤: ការលើកលែងអោយរួចពីការរឹបអូស ការចាប់ និងការចាប់យកជាជ័យភ័ណ្ឌ

១- ការលើកលែងអោយរួចពីការរឹបអូស ការចាប់ ឬការចាប់យកជាជ័យភ័ណ្ឌ នឹងត្រូវគេផ្តល់ដល់:

ក- សម្បត្តិវប្បធម៌ដែលបានទទួលការការពារដូចមានចែងទុកក្នុងមាត្រា១២ ឬមាត្រា១៣

ខ- មធ្យោបាយដឹកនាំដែលប្រើប្រាស់ផ្តាច់មុខដើម្បីដឹកជញ្ជូនសម្បត្តិវប្បធម៌ទាំងនោះ ។

២- គ្មានហេតុផលណាមួយនៅក្នុងមាត្រានេះ នឹងត្រូវដាក់កំហិតរឹតត្បិតទៅលើសិទ្ធិនៃការធ្វើទស្សនកិច្ច និងសិទ្ធិក្នុងការស្រាវជ្រាវឡើយ ។

## ជំពូកទី៤

## បុគ្គលិក

## មាត្រា១៥: បុគ្គលិក

អាស្រ័យដោយសារសំខាន់នៃសន្តិសុខ បុគ្គលិកដែលមានភារកិច្ចការពារសម្បត្តិវប្បធម៌ដើម្បីផលប្រយោជន៍នៃសម្បត្តិវប្បធម៌ទាំងនេះនឹងត្រូវបានទទួលការគោរព ហើយប្រសិនបើបុគ្គលិកទាំងនេះត្រូវធ្លាក់ទៅក្នុងកណ្តាប់ដៃភាគីបច្ចាមិត្ត ពួកគេនឹងត្រូវបានការអនុញ្ញាតិអោយបន្តអនុវត្តកាតព្វកិច្ចរបស់គេ

នៅគ្រប់ពេលដែលសម្បត្តិវប្បធម៌ដែលបុគ្គលិកទាំងនេះទទួលខុសត្រូវ ក៏ត្រូវធ្លាក់ទៅក្នុងកណ្ដាប់ដៃនៃបដិភាគីដែរនោះ ។

## ជំពូកទី៥

## ផ្លាកសញ្ញាសំគាល់

### មាត្រា១៦: ផ្លាកសញ្ញាសំគាល់របស់អនុសញ្ញា

១- ផ្លាកសញ្ញាសំគាល់នៃអនុសញ្ញានេះមានរាងជាខែលស្រួចចុងខាងក្រោម និងញែកផ្ដាច់គ្នាដោយពណ៌ផ្ទៃមេឃ និងពណ៌ស (គឺជាខែលមួយមានរាងចតុកោណកែងស្មើពណ៌ផ្ទៃមេឃភ្លឺ ដែលមុំមួយក្នុងចំណោមមុំនៃចតុកោណកែងស្មើនោះ ចារឹកបានជាចុងស្រួចនៃខែល ហើយចាប់ពីត្រីកោណពណ៌ផ្ទៃមេឃភ្លឺមួយដែលនៅទល់កំពូលគ្នាជាមួយមុំមួយនៃចតុកោណកែងស្មើ គឺត្រីកោណពណ៌សពីរ បានបំពេញផ្ទៃនៅសល់ទាំងសង្ខាងនោះ) ។

២- ផ្លាកសញ្ញានឹងត្រូវគេប្រើតែមួយ ឬក៏ប្រើម្ដងបី ក្នុងពេលជាមួយគ្នា ដោយតំរៀបវាជាទំរង់ត្រីកោណ (ខែលមួយនៅពីក្រោម) ក្រោមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងមាត្រា១៧ ។

### មាត្រា១៧: ការប្រើប្រាស់ផ្លាកសញ្ញាសំគាល់

១- ផ្លាកសញ្ញាសំគាល់ដែលគេដាក់ម្ដងបី អាចត្រូវបានប្រើប្រាស់ដើម្បីសំគាល់:

ក- អចលនសម្បត្តិវប្បធម៌ស្ថិតក្រោមការការពារពិសេស

ខ- ការដឹកនាំសម្បត្តិវប្បធម៌នៅក្រោមការការពារពិសេស ដូចបានចែងក្នុងមាត្រា១២ និង១៣

គ- អគារទាំងឡាយណាដែលប្រើសំរាប់ការពារសម្បត្តិវប្បធម៌ ក្រោមល័ក្ខខ័ណ្ឌដូចមានចែងក្នុងបទបញ្ជាសំរាប់អនុវត្តអនុសញ្ញា ។

២- គេអាចប្រើប្រាស់ផ្លាកសញ្ញាសំគាល់តែមួយ ដើម្បីសំគាល់:

ក- សម្បត្តិវប្បធម៌ដែលពុំស្ថិតនៅក្រោមការការពារពិសេស

ខ- បុគ្គលទទួលខុសត្រូវការងារត្រួតពិនិត្យ អនុលោមតាមបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញា

គ- បុគ្គលិកដែលជាប់ទាក់ទិនក្នុងការងារការពារសម្បត្តិវប្បធម៌

ឃ- អត្តសញ្ញាណប័ណ្ណដែលមានអធិប្បាយនៅក្នុងបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញា ។

៣- ក្នុងកំឡុងពេលនៃវិវាទប្រដាប់អាវុធ ការប្រើប្រាស់ផ្លាកសញ្ញាក្នុងករណីណាមួយក្រៅពីករណីដែលមានចែងនៅក្នុងបណ្ដាកថាខ័ណ្ឌខាងលើនៃមាត្រានេះ ហើយនិងការប្រើប្រាស់សំរាប់គោលដៅណាមួយដែលប្រើសញ្ញាប្រហាក់ប្រហែលនឹងផ្លាកសញ្ញានេះ គឺត្រូវហាមឃាត់ ។

៤- គេពុំអាចដាក់ផ្លាកសញ្ញាទៅលើអចលនសម្បត្តិវប្បធម៌ណាមួយបានទេ លុះត្រាតែក្នុងពេលជាមួយគ្នានោះ គេត្រូវដាក់បង្ហាញផងដែរនូវច្បាប់អនុញ្ញាតដែលមានចុះកាលបរិច្ឆេទ និងហត្ថលេខាយ៉ាងត្រឹមត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសចុះកិច្ចសន្យានោះ ។

## ជំពូកទី៦

## ទំហំនៃការអនុវត្តអនុសញ្ញា

### មាត្រា១៨: ការអនុវត្តអនុសញ្ញា

១- ក្រៅពីមាត្រាបញ្ញត្តិទាំងឡាយដែលនឹងមានប្រសិទ្ធិភាពក្នុងពេលមានសន្តិភាព អនុសញ្ញានេះអាចយកទៅប្រើប្រាស់បាននៅក្នុងករណីមានការប្រកាសសង្គ្រាម ឬក្នុងពេលមានជំលោះប្រដាប់អាវុធដទៃទៀត ដែលអាចនឹងកើតឡើងរវាងប្រទេសចុះកិច្ចសន្យាពីរ ឬច្រើន ទោះបីជាស្ថានភាពសង្គ្រាមពុំត្រូវបានទទួលស្គាល់ដោយប្រទេសណាមួយក្នុងចំណោមប្រទេសទាំងនោះក៏ដោយ ។

២- អនុសញ្ញានេះក៏មានប្រសិទ្ធិភាពផងដែរ ចំពោះគ្រប់ករណីទាំងអស់នៃការចូលកាន់កាប់ទឹកដីមួយផ្នែក ឬទាំងមូល របស់ប្រទេសចុះកិច្ចសន្យាមួយ ទោះបីជាការចូលកាន់នោះពុំបានទទួលការប្រឆាំងដោយអាវុធក្ដី ។

៣- ទោះបីជាមានប្រទេសណាមួយ ក្នុងចំណោមប្រទេសដែលចូលរួមក្នុងជំលោះ ពុំមែនជាសមាជិកនៃអនុសញ្ញានេះក៏ដោយ ក៏បណ្ដាប្រទេសដែលជាសមាជិកនៅតែអនុវត្តអនុសញ្ញានេះ នៅក្នុងចំណងទាក់ទងជាបដិការដែរ ។ លើសពីនេះទៅទៀត ប្រទេសជាសមាជិកក៏នឹងត្រូវតែអនុវត្តអនុសញ្ញានេះដែរ នៅក្នុងទំនាក់ទំនងជាមួយប្រទេសមួយទៀតដែលពុំមែនជាសមាជិកអនុសញ្ញានេះ ប្រសិនបើប្រទេសក្រោយនេះយល់ព្រមទទួលយកនូវបញ្ញត្តិទាំងឡាយនៃអនុសញ្ញា ហើយថែមទាំងអនុវត្តតាមទៀតនោះ ។

### មាត្រា១៩: ជំលោះដែលពុំមែនជាជំលោះអន្តរជាតិ

១- ចំពោះវិវាទប្រដាប់អាវុធណាមួយដែលពុំមានចរិតជាជំលោះអន្តរជាតិ និងដែលកើតមានឡើងនៅលើទឹកដីនៃប្រទេសចុះកិច្ចសន្យាមួយ ភាគីនីមួយៗដែលចូលរួមនៅក្នុងជំលោះនោះនឹងនៅតែរក្សាបំណាង

អនុវត្តជានិច្ច យ៉ាងហោចណាស់ គឺមាត្រាបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះដែលពាក់ព័ន្ធទៅនឹងការគោរពសម្បត្តិវប្បធម៌ដែរ ។

២- បណ្តាភាគីក្នុងជំលោះ នឹងខិតខំដាក់អោយចូលជាធរមាន តាមរយៈកិច្ចសន្យាព្រមព្រៀងពិសេសទាំងឡាយ នូវបញ្ញត្តិទាំងអស់ ឬផ្នែកខ្លះៗនៃអនុសញ្ញានេះ ។

៣- អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ អាចជួយជ្រោមជ្រែងសំរួលការជូនដល់បណ្តាភាគីដែលពាក់ព័ន្ធក្នុងជំលោះ ។

៤- ការអនុវត្តមាត្រាបញ្ញត្តិទាំងឡាយដែលបានរៀបរាប់ពីខាងដើមមកនេះ នឹងពុំជះឥទ្ធិពលទៅលើស្ថានភាពផ្លូវច្បាប់របស់ភាគីដែលពាក់ព័ន្ធក្នុងវិវាទឡើយ ។

## ជំពូកទី៧

## ការអនុវត្តអនុសញ្ញា

### មាត្រា២០: បទបញ្ជាសំរាប់អនុវត្តអនុសញ្ញា

បទដ្ឋានដែលប្រើប្រាស់ដើម្បីអនុវត្តអនុសញ្ញានេះ ត្រូវបានបញ្ជាក់ច្បាស់នៅក្នុងបទបញ្ជាសំរាប់ការអនុវត្ត ដែលនឹងរួមបញ្ចូលគ្នាទៅក្នុងផ្នែកទាំងមូលនៃអនុសញ្ញានេះ ។

### មាត្រា២១: អាជ្ញាធរការពារ

អនុសញ្ញានេះរួមជាមួយបទបញ្ជាសំរាប់ការអនុវត្ត នឹងត្រូវគេអនុវត្តឡើងដោយមានកិច្ចសហប្រតិបត្តិការពីសំណាក់អាជ្ញាធរការពារ ដែលទទួលខុសត្រូវថែរក្សាផលប្រយោជន៍របស់ប្រទេសដែលពាក់ព័ន្ធក្នុងជំលោះ ។

### មាត្រា២២: វិធីសាស្ត្រសំរុះសំរួល

១- អាជ្ញាធរការពារ នឹងផ្តល់ការឧបត្ថម្ភរបស់ខ្លួនក្នុងគ្រប់ករណីទាំងអស់ដែលខ្លួនយល់ថាជាការចាំបាច់ និងមានប្រយោជន៍ដល់សម្បត្តិវប្បធម៌ ជាពិសេសប្រសិនបើមានការខ្វែងគំនិតគ្នារវាងបណ្តាប្រទេសក្នុងជំលោះ លើការអនុវត្ត ឬការបកស្រាយមាត្រាបញ្ញត្តិទាំងឡាយនៃអនុសញ្ញា ឬមាត្រាបញ្ញត្តិទាំងឡាយរបស់បទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញានេះ ។

២- សំរាប់គោលបំណងនេះ អាជ្ញាធរការពារនីមួយៗ តាមរយៈការអញ្ជើញរបស់ភាគីមួយ ឬរបស់លោកអគ្គនាយកអង្គការ អប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ឬតាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ អាចស្នើដល់បណ្តាប្រទេសក្នុងជំលោះអោយមានការជួបប្រជុំនូវតំណាងរបស់ខ្លួន និងជាពិសេសការជួប

៦

ប្រជុំនៃអាជ្ញាធរដែលទទួលខុសត្រូវក្នុងការការពារសម្បត្តិវប្បធម៌ ប្រសិនបើគេចាត់ទុកថាជាការសមរម្យ នៅលើទឹកដីអព្យាក្រឹតមួយដែលត្រូវបានជ្រើសរើសយ៉ាងសមស្រប ។ បណ្ដាប្រទេសក្នុងជំលោះត្រូវតែផ្ដល់ការយល់ព្រម ចំពោះករណីមានការស្នើសុំអោយមានការជួបប្រជុំ ដែលគេលើកឡើងចំពោះខ្លួន ។ អាជ្ញាធរការពារនឹងដាក់សំណើសុំសេចក្ដីយល់ព្រមពីសំណាក់ប្រទេសក្នុងជំលោះ សុំតែងតាំងបុគ្គលម្នាក់ដែលមកពីប្រទេសអព្យាក្រឹត ឬក៏ជាបុគ្គលដែលតែងតាំងឡើងដោយលោកអគ្គនាយកអង្គការ អប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ដែលនឹងត្រូវអញ្ជើញអោយចូលរួមក្នុងកិច្ចប្រជុំ ក្នុងឋានៈជាប្រធាន ។

## មាត្រា២៣: សហប្រតិបត្តិការរបស់អង្គការ អប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ

១- ប្រទេសចុះកិច្ចសន្យាទាំងអស់អាចស្នើសុំអង្គការ អប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិនូវជំនួយផ្នែកបច្ចេកទេសនៅក្នុងការរៀបចំការការពារសម្បត្តិវប្បធម៌របស់ខ្លួន ឬទាក់ទងអំពីបញ្ហាដទៃទៀតដែលកើតចេញពីការអនុវត្តអនុសញ្ញា ឬក៏ការអនុវត្តបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញានេះ ។ អង្គការនឹងយល់ព្រមផ្ដល់ជំនួយក្នុងក៏រិតមួយដែលកំណត់ដោយកម្មវិធី និងប្រភពថវិការបស់ខ្លួន ។
២- អង្គការ អប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ មានសិទ្ធិធ្វើគំរោងសំណើតាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន នៅលើបញ្ហាទាំងនេះជូនប្រទេសចុះកិច្ចសន្យា ។

## មាត្រា២៤: កិច្ចព្រមព្រៀងពិសេស

១- ប្រទេសចុះកិច្ចសន្យាទាំងអស់ អាចធ្វើកិច្ចព្រមព្រៀងពិសេសសំរាប់បញ្ហាទាំងអស់ដែលទាក់ទិនហើយដែលគេចាត់ទុកថាមានលក្ខណៈសមស្របក្នុងការបង្កើតបញ្ញត្តិពិសេសដោយឡែក ។
២- គេពុំអាចធ្វើកិច្ចព្រមព្រៀងពិសេសណាមួយ ដែលប្រែទៅជាកាត់បន្ថយកិច្ចការពារដែលបានប្រឹងប្រែងធ្វើឡើងដោយអនុសញ្ញានេះចំពោះសម្បត្តិវប្បធម៌ និងចំពោះបុគ្គលិកដែលពាក់ព័ន្ធក្នុងការងារការពារសម្បត្តិវប្បធម៌បានឡើយ ។

## មាត្រា២៥: ការផ្សព្វផ្សាយអនុសញ្ញា

ប្រទេសចុះកិច្ចសន្យាទាំងអស់យល់ព្រម ទាំងក្នុងពេលមានសន្តិភាព ទាំងក្នុងពេលមានវិវាទប្រដាប់អាវុធផ្សព្វផ្សាយអត្ថបទនៃអនុសញ្ញា និងបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញានេះអោយបានទូលំទូលាយ តាមដែលអាចធ្វើទៅបាន នៅក្នុងប្រទេសរបស់ផងខ្លួន។ ប្រទេសចុះកិច្ចសន្យាទាំងអស់យល់ព្រម ជាពិសេស

បញ្ចូលការសិក្សាលើបញ្ហានេះ ចូលទៅក្នុងកម្មវិធីហ្វឹកហ្វឺនយោធា និងប្រសិនបើអាច គឺទៅក្នុងកម្មវិធីបណ្តុះបណ្តាលស៊ីវិល ដើម្បីអោយគោលការណ៍របស់អនុសញ្ញាត្រូវបានទទួលស្គាល់ដឹងឮនៅក្នុងស្រទាប់មហាជនទាំងមូល ជាពិសេសក្នុងជួរកងកំលាំងប្រដាប់អាវុធ និងបុគ្គលិកដែលពាក់ព័ន្ធដល់ការងារការពារសម្បត្តិវប្បធម៌។

## មាត្រា២៦: ការបញ្ជូនសារ និងរបាយការណ៍

១- ប្រទេសចុះកិច្ចសន្យាទាំងអស់នឹងទាក់ទងគ្នាទៅវិញទៅមក តាមរយៈលោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ នូវឯកសារជូនដំណឹងផ្លូវការដែលពាក់ព័ន្ធទៅនឹងការអនុវត្តអនុសញ្ញា និងបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញានេះ។

២- លើសពីនេះទៀត យ៉ាងហោចណាស់ក៏ក្នុងរយៈពេលបួនឆ្នាំម្តង ប្រទេសចុះកិច្ចសន្យាទាំងអស់នឹងបញ្ជូនទៅលោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ នូវរបាយការណ៍មួយច្បាប់ ស្តីអំពីពត៌មាននានាដែលគេគិតថាសមស្រប ទាក់ទិនដល់វិធានការទាំងឡាយដែលកំពុងតែអនុវត្ត ដែលបានរៀបចំ ឬដែលត្រៀមនឹងអនុវត្ត ដោយស្ថាប័នជំនាញនីមួយៗរបស់ប្រទេសខ្លួន ជាកិច្ចដើម្បីបំពេញតាមអនុសញ្ញា និងបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញានេះ។

## មាត្រា២៧: ការជួបប្រជុំ

១- លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ដោយមានការយល់ព្រមពីគណៈកម្មាធិការប្រតិបត្តិអាចកោះប្រជុំតំណាងនៃបណ្តាប្រទេសចុះកិច្ចសន្យា។ លោកអគ្គនាយកត្រូវកោះប្រជុំបែបនេះ ប្រសិនបើយ៉ាងហោចណាស់មានប្រទេសចំនួនមួយភាគបួន នៃបណ្តាប្រទេសចុះកិច្ចសន្យាលើកសំណូមពរឡើង។

២- ដោយគ្មានលំអៀងចំពោះតួនាទីណាមួយដែលផ្តល់អោយដោយអនុសញ្ញា ឬបទបញ្ជាសំរាប់ការអនុវត្ត គោលបំណងនៃការជួបប្រជុំគឺ សិក្សាលើបញ្ហាដែលទាក់ទិនដល់ការអនុវត្តអនុសញ្ញា និងការអនុវត្តបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញា ហើយនិងដើម្បីដាក់ចុះនូវអនុសាសន៍នានា ដែលសមស្របទៅនឹងរាល់បញ្ហាទាំងនោះ។

៣- លើសពីនេះទៀត ការប្រជុំអាចធ្វើការពិនិត្យឡើងវិញលើអនុសញ្ញា ឬបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញា ប្រសិនបើមានប្រទេសចុះកិច្ចសន្យាភាគច្រើនលើកសំណើសុំ ហើយដែលសមស្របទៅតាមបញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងមាត្រា៣៩។

## មាត្រា២៨: ទោសបញ្ញត្តិ

ប្រទេសចុះកិច្ចសន្យាទាំងអស់យល់ព្រមអនុវត្ត នៅក្នុងរង្វង់នៃប្រព័ន្ធយុត្តាធិការព្រហ្មទ័ណ្ឌរបស់ខ្លួន នូវរាល់វិធានការដើម្បីដាក់ទ័ណ្ឌកម្មព្រហ្មទ័ណ្ឌ ឬទ័ណ្ឌកម្មជាពិន័យផ្សេងៗទៀត ទៅលើបុគ្គលទាំងឡាយណា ដោយមិនរាប់ថាជាសញ្ជាតិណាឡើយ ដែលបានប្រព្រឹត្ត ឬដែលបានចាត់បញ្ជាអោយគេប្រព្រឹត្តអំពើរំលោភបំពានលើអនុសញ្ញានេះ ។

## អវសានបញ្ញត្តិ

## មាត្រា២៩: ភាសា

១- អត្ថបទនៃអនុសញ្ញានេះត្រូវបានតាក់តែងឡើងជាភាសាអង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ៉ុល ហើយអត្ថបទទាំងបួនភាសានេះមានតំលៃស្មើគ្នាតាមផ្លូវច្បាប់ ។

២- អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ នឹងរៀបចំអោយមានការបកប្រែអនុសញ្ញានេះជាភាសាផ្លូវការដទៃទៀតរបស់មហាសន្និបាតរបស់ខ្លួន ។

## មាត្រា៣០: ការចុះហត្ថលេខា

អនុសញ្ញានេះ នឹងចុះកាលបរិច្ឆេទនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥៤ និងរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៥៤ នឹងស្ថិតនៅជាចំហសំរាប់ការចុះហត្ថលេខាពីសំណាក់ប្រទេសទាំងអស់ដែលត្រូវបានអញ្ជើញអោយចូលរួមក្នុងកិច្ចប្រជុំនៅទីក្រុងឡាអេ ពីថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៥៤ ដល់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥៤ ។

## មាត្រា៣១: ការផ្តល់សច្ចានុម័ត

១- អនុសញ្ញានេះនឹងត្រូវបានទទួលការផ្តល់សច្ចានុម័តពីសំណាក់រដ្ឋហត្ថលេខី ស្របទៅតាមទំរង់ការនៃរដ្ឋធម្មនុញ្ញរបស់ប្រទេសគេផ្ទាល់ ។

២- ឯកសារផ្លូវការនៃការផ្តល់សច្ចានុម័ត នឹងត្រូវប្រគល់ជូនទៅលោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ។

## មាត្រា៣២: ការចូលជាសមាជិក

គិតចាប់ពីកាលបរិច្ឆេទដែលចូលជាធរមាន អនុសញ្ញានេះនឹងស្ថិតនៅជាចំហសំរាប់ការសុំចូលបន្ថែមជាសមាជិកពីសំណាក់ប្រទេសទាំងឡាយ ដូចមានអធិប្បាយយោងក្នុងមាត្រា៣០ ដែលពុំទាន់បានចុះហត្ថលេខាលើអនុសញ្ញានេះ ក៏ដូចជាបណ្តាប្រទេសដទៃទៀត ដែលបានទទួលការអញ្ជើញអោយចូលជា

សមាជិក ពីសំណាក់គណៈកម្មការប្រតិបត្តិ របស់អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ។ ការសុំចូលជាសមាជិក ត្រូវធ្វើឡើងដោយការផ្តល់ឯកសារផ្លូវការនៃការសុំចូលជាសមាជិក ដល់លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ។

## មាត្រា៣៣: ការចូលជាធរមាន

១- អនុសញ្ញានេះនឹងចូលជាធរមាននៅរយៈពេលបីខែ បន្ទាប់ពីឯកសារផ្លូវការនៃការផ្តល់សច្ចានុម័តចំនួនប្រាំច្បាប់ ត្រូវបានគេផ្តល់ជូន។

២- បន្ទាប់ពីនេះ វានឹងចូលជាធរមានសំរាប់ប្រទេសចុះកិច្ចសន្យានីមួយៗ នៅរយៈពេលបីខែ បន្ទាប់ពីប្រទេសនោះផ្តល់ឯកសារផ្លូវការនៃការផ្តល់សច្ចានុម័ត ឬឯកសារផ្លូវការនៃការសុំចូលជាសមាជិក។

៣- ស្ថានភាពដែលមានចែងនៅក្នុងមាត្រា១៨ និង១៩ នឹងផ្តល់អនុភាពភ្លាមដល់សច្ចានុម័ត ឬការសុំចូលជាសមាជិក ដែលដាក់ធ្វើឡើងដោយប្រទេសពាក់ព័ន្ធក្នុងជំលោះ ទាំងមុនឬក្រោយការចាប់ផ្តើមនៃអរិភាព ឬការចូលកាន់កាប់ទឹកដី។ ក្នុងករណីបែបនេះ លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ត្រូវបញ្ជូនពត៌មានដែលមានចែងនៅក្នុងមាត្រា៣៨ តាមវិធីយ៉ាងឆាប់បំផុត។

## មាត្រា៣៤: ការអនុវត្តមានប្រសិទ្ធិភាព

១- ប្រទេសចុះកិច្ចសន្យានីមួយៗនៃអនុសញ្ញា នៅពេលដែលអនុសញ្ញាចូលជាធរមាន ត្រូវចាត់គ្រប់វិធានការចាំបាច់ទាំងឡាយ ដើម្បីធានាដល់ការអនុវត្តដ៏មានប្រសិទ្ធិភាពក្នុងរយៈពេលប្រាំមួយខែ បន្ទាប់ពីអនុសញ្ញាចូលជាធរមាន។

២- រយៈពេលនេះគឺ៦ខែ គឺរាប់ចាប់ពីកាលបរិច្ឆេទនៃការផ្តល់ឯកសារផ្លូវការនៃការផ្តល់សច្ចានុម័ត ឬឯកសារផ្លូវការនៃការសុំចូលជាសមាជិក សំរាប់ប្រទេសទាំងអស់ដែលផ្តល់ឯកសារផ្លូវការនៃការផ្តល់សច្ចានុម័ត ឬឯកសារផ្លូវការនៃការសុំចូលជាសមាជិករបស់ខ្លួន ក្រោយពេលអនុសញ្ញាបានចូលជាធរមានទៅហើយនោះ។

## មាត្រា៣៥: ការផ្សព្វផ្សាយអនុសញ្ញានៅក្នុងទឹកដីប្រទេស

ប្រទេសចុះកិច្ចសន្យានីមួយៗ នៅពេលចុះហត្ថលេខាផ្តល់សច្ចានុម័ត ឬសុំចូលជាសមាជិក ឬនៅពេលណាមួយក្រោយពីពេលនោះ អាចប្រកាសដោយផ្តល់ពត៌មានដល់លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ថា អនុសញ្ញានេះនឹងត្រូវផ្សព្វផ្សាយនៅទូទាំងដែនដី ឬទូទាំងដែនដីណា

មួយដែលប្រទេសខ្លួនទទួលខុសត្រូវផ្នែកទំនាក់ទំនងអន្តរជាតិ ។ ការផ្តល់ពត៌មានដូចមានអធិប្បាយខាងដើមនេះ នឹងមានប្រសិទ្ធិភាពបន្ទាប់ពីរយៈពេលបីខែ ក្រោយកាលបរិច្ឆេទនៃការទទួល ។

## មាត្រា៣៦: ទំនាក់ទំនងចំពោះបណ្តាអនុសញ្ញាពីពេលមុន

១- ក្នុងទំនាក់ទំនងរវាងមហាអំណាចទាំងឡាយ ដែលជាប់សន្យានៅក្នុងបណ្តាអនុសញ្ញាទីក្រុងឡាអេ ស្តីអំពីច្បាប់និងទំនៀមទំលាប់នៃសង្គ្រាមលើដី (IV) និងអនុសញ្ញាដែលស្តីអំពី *ការបាញ់កាំភ្លើងនៃកងទាហានជើងទឹកក្នុងពេលមានសង្គ្រាម*(IX) ទោះជាអនុសញ្ញាដែលចុះកាលបរិច្ឆេទថ្ងៃទី២៩ កក្កដា ឆ្នាំ១៨៩៩ ឬក៏អនុសញ្ញាដែលចុះកាលបរិច្ឆេទថ្ងៃទី១៨ តុលា ឆ្នាំ១៩០៧ ក៏ដោយ ហើយដែលបានក្លាយជាសមាជិកអនុសញ្ញានេះក្តី អនុសញ្ញាចុងក្រោយនេះនឹងបានជាការបំពេញបន្ថែមទៅលើអនុសញ្ញាដូចបានចែងពីខាងលើនេះ (IX) និងទៅលើបទបញ្ញាដែលជាឧបសម្ព័ន្ធរបស់អនុសញ្ញាដូចបានចែងពីខាងលើ (IV)ហើយ នឹងជំនួសអោយផ្លាកសញ្ញាដូចមានអធិប្បាយក្នុងមាត្រា៥ នៃអនុសញ្ញាដែលបានចែងពីខាងលើ(IX) ដោយផ្លាកសញ្ញាដែលបានអធិប្បាយនៅក្នុងមាត្រា១៦ នៃអនុសញ្ញានេះ ក្នុងករណីដែលអនុសញ្ញា និងបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញាចុងក្រោយនេះ ផ្តល់អោយមានការប្រើប្រាស់នូវផ្លាកសញ្ញានេះ ។

២- ក្នុងទំនាក់ទំនងរវាងមហាអំណាចទាំងឡាយដែលជាប់សន្យានឹងកតិកាសញ្ញាវ៉ាស៊ីងតោន ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៣៥ ស្តីពីការការពារបណ្តាវិមានសិល្បៈ និងវិទ្យាសាស្ត្រ និងសំណង់ប្រវត្តិសាស្ត្រ (កតិកាសញ្ញា ROERICH) និងដែលជាសមាជិកនៃអនុសញ្ញានេះ អនុសញ្ញាក្រោយនេះនឹងបានជាការបំពេញបន្ថែមទៅលើកតិកាសញ្ញា ROERICH ហើយនឹងជំនួសអោយទង់ដែលមានអធិប្បាយនៅក្នុងមាត្រាទី III នៃកតិកាសញ្ញា នូវផ្លាកសញ្ញាដែលមានរៀបរាប់ក្នុងមាត្រា១៦ នៃអនុសញ្ញានេះ ក្នុងករណីដែលអនុសញ្ញា និងបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញានេះ ផ្តល់អោយមានការប្រើប្រាស់ផ្លាកសញ្ញានេះ ។

## មាត្រា៣៧: ការប្រកាសបដិសេធវិញ

១- ប្រទេសចុះកិច្ចសន្យានីមួយៗ អាចប្រកាសបដិសេធលុបចោលអនុសញ្ញានេះវិញបានដោយតាងនាមខ្លួនផ្ទាល់ ឬតាងនាមអោយដែនដីណាមួយដែលប្រទេសនោះទទួលខុសត្រូវផ្នែកទំនាក់ទំនងអន្តរជាតិ ។

២- ការប្រកាសបដិសេធ នឹងត្រូវធ្វើឡើងជាឯកសារផ្លូវការដោយលាយលក្ខណ៍អក្សរ ដែលត្រូវបញ្ជូនទៅលោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ។

៣- ការប្រកាសបដិសេធ នឹងបានទទួលអនុភាពគតិយុត្តិនៅរយៈពេលមួយឆ្នាំ ក្រោយពីគេបានទទួលឯកសារផ្លូវការនៃការប្រកាសបដិសេធ ។ យ៉ាងណាក្តី ប្រសិនបើនៅពេលផុតកំណត់នៃរយៈពេលនេះ ប្រទេសដែលប្រកាសបដិសេធមិនទាក់ទិននៅក្នុងវិវាទប្រដាប់អាវុធណាមួយនោះ ការប្រកាសបដិសេធនោះនឹងពុំបានទទួលប្រសិទ្ធិភាពឡើយ រហូតទាល់តែសកម្មភាពអមិត្តនោះត្រូវបានបញ្ចប់ ឬរហូតទាល់តែប្រតិបត្តិការនៃការបញ្ជូនសម្បត្តិវប្បធម៌ត្រឡប់ទៅកន្លែងដើមវិញ ត្រូវបានបញ្ចប់រួចរាល់ហើយសិន ទើបការប្រកាសបដិសេធខាងលើនឹងបានចូលជាធរមានជាក្រោយ ។

## មាត្រា៣៨: ការផ្តល់ពត៌មាន

លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ត្រូវផ្តល់ពតិមានដល់បណ្តាប្រទេសទាំងឡាយដែលមានអធិប្បាយនៅក្នុងមាត្រា៣០ និង៣២ ក៏ដូចជាដល់អង្គការសហប្រជាជាតិដែរ ស្តីអំពីការផ្តល់ឯកសារផ្លូវការនៃការផ្តល់សច្ចានុម័ត ការផ្តល់ឯកសារផ្លូវការនៃការដាក់ពាក្យសុំចូលជាសមាជិក ឬការផ្តល់ពតិមានដែលមានចែងនៅក្នុងមាត្រា៣១ ៣២ និង៣៩ និងស្តីអំពីការផ្តល់ពតិមាន និងការប្រកាសបដិសេធដែលមានអធិប្បាយនៅក្នុងមាត្រា៣៥ ៣៧ និង៣៩ ។

## មាត្រា៣៩: វិសោធនកម្មនៃអនុសញ្ញា និងបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញា

១- ប្រទេសចុះកិច្ចសន្យាណាក៏ដោយ ក៏សុទ្ធតែអាចលើកសំណើសុំធ្វើវិសោធនកម្មលើអនុសញ្ញា ឬលើបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញានេះ ។ អត្ថបទនៃវិសោធនកម្មដែលគេស្នើសុំ នឹងត្រូវផ្តល់ជូនដល់លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ដែលលោកត្រូវបញ្ជូនសំណើនោះដល់ប្រទេសចុះកិច្ចសន្យានីមួយៗ ជាមួយនឹងសំណូមពរអោយប្រទេសទាំងនោះឆ្លើយតបមកវិញក្នុងកំឡុងពេល៤ខែ ដោយបញ្ជាក់ថាខ្លួន:

ក- មានបំណងអោយកោះបើកសន្និសីទមួយ ដើម្បីពិចារណានូវវិសោធនកម្មដែលស្នើឡើង

ខ- មានបំណងទទួលយកនូវវិសោធនកម្មដែលស្នើឡើង ដោយពុំចាំបាច់មានសន្និសីទ ឬ

គ- មានបំណងបដិសេធសំណើវិសោធនកម្មដោយពុំចាំបាច់បើកសន្និសីទ ។

២- លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ត្រូវបញ្ជូនចំលើយដែលបានទទួលដូចបានរៀបរាប់ក្នុងកថាខ័ណ្ឌទី១ នៃមាត្រានេះ ទៅអោយប្រទេសចុះកិច្ចសន្យាទាំងអស់ ។

៣- ប្រសិនបើប្រទេសចុះកិច្ចសន្យាទាំងអស់ ក្នុងកំឡុងពេលកំណត់ បានបញ្ជាក់នូវទស្សនៈរបស់ខ្លួនជូនដល់លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ស្របទៅតាមកថាខ័ណ្ឌ

ទី១ ខ នៃមាត្រានេះ ថាខ្លួនមានបំណងទទួលយកវិសោធនកម្មដោយគ្មានសន្និសីទការផ្តល់ពតិមាន ស្តីពីការសំរេចចិត្តរបស់គេនឹងត្រូវធ្វើឡើងដោយលោកអគ្គនាយក ដោយអនុលោមទៅតាមមាត្រា៣៨។ វិសោធនកម្ម និងមានអនុភាពគតិយុត្តិសំរាប់ប្រទេសចុះកិច្ចសន្យាទាំងអស់ នៅក្រោយ៩០ថ្ងៃ រាប់ពី កាលបរិច្ឆេទនៃការផ្តល់ពតិមាននេះ។

៤- លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ត្រូវកោះបើកសន្និសីទនៃ បណ្តាប្រទេសចុះកិច្ចសន្យាដើម្បីពិនិត្យពិចារណាលើសំណើសុំធ្វើវិសោធនកម្ម ប្រសិនបើមានលើសពីមួយ ភាគពីរ នៃប្រទេសចុះកិច្ចសន្យាស្នើសុំដូច្នេះ។

៥- វិសោធនកម្មលើអនុសញ្ញា ឬលើបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញាដែលបានដាក់អោយស្ថិតនៅ ក្រោមបែបបទដូចបាននិយាយយោងក្នុងកថាខ័ណ្ឌមុននេះ នឹងចូលជាធរមាន តែនៅក្រោយពេលដែល ប្រទេសចុះកិច្ចសន្យាទាំងអស់បានអនុម័តជាឯកច្ឆ័ន្ទនៅក្នុងសន្និសីទ និងត្រូវបានយល់ព្រមទទួលយក ដោយប្រទេសចុះកិច្ចសន្យាទាំងអស់តែប៉ុណ្ណោះ។

៦- ការយល់ព្រមទទួលយកដោយប្រទេសចុះកិច្ចសន្យាទាំងអស់ នូវវិសោធនកម្មនៃអនុសញ្ញា ឬវិសោធ នកម្មនៃបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញា ដែលបានអនុម័តដោយសន្និសីទ ដូចមានអធិប្បាយនៅក្នុង កថាខ័ណ្ឌទី៤ និងទី៥ នៃមាត្រានេះ នឹងចូលជាធរមានដោយការផ្តល់ឯកសារផ្លូវការ ជូនចំពោះលោក អគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ។

៧- បន្ទាប់ពីការចូលជាធរមានរបស់វិសោធនកម្មនៃអនុសញ្ញា ឬវិសោធនកម្មនៃបទបញ្ជាសំរាប់ការ អនុវត្តអនុសញ្ញា គឺមានតែអត្ថបទនៃអនុសញ្ញា ឬបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញាដែលបានធ្វើ វិសោធនកម្មនេះទេ ដែលនឹងស្ថិតនៅជាចំហសំរាប់ការផ្តល់សច្ចានុម័ត ឬការសុំចូលជាសមាជិក។

## មាត្រា៤០: ការចុះបញ្ជី

អនុលោមតាមមាត្រា១០២ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ អនុសញ្ញានេះនឹងត្រូវចុះបញ្ជីនៅ នឹងលេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិ តាមសំណើរបស់លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ។

នៅក្នុងភក្តីភាព និងសមត្ថកិច្ចដ៏បរិបូរណ៍ ហត្ថលេខីទាំងអស់ បានចុះហត្ថលេខាលើអនុសញ្ញានេះ។

ធ្វើនៅទីក្រុងឡាអេ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥៤ ជាច្បាប់តែមួយគត់ដែលនឹងត្រូវតំកល់ទុកនៅក្នុង ប័ណ្ណសារដ្ឋានរបស់អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ហើយច្បាប់ចំលងដែល

បញ្ជាក់ថាត្រឹមត្រូវ នឹងត្រូវផ្ញើជូនដល់ប្រទេសទាំងអស់ដូចបាននិយាយយោងនៅក្នុងមាត្រា៣០ និង៣២ រួមទាំងអង្គការសហប្រជាជាតិផងដែរ ។

**បទបញ្ជាសំរាប់ការអនុវត្ត**

**អនុសញ្ញាស្តីអំពីការការពារសម្បត្តិវប្បធម៌**

**ក្នុងគ្រាមានជំលោះប្រដាប់អាវុធ**

## ជំពូកទី១

## ការត្រួតពិនិត្យ

### មាត្រា១: បញ្ជីអន្តរជាតិរាយនាមបុគ្គល

នៅពេលអនុសញ្ញាចូលជាធរមាន លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ត្រូវបង្កើតបញ្ជីអន្តរជាតិមួយ ដែលរួមមានឈ្មោះបុគ្គលទាំងអស់ដែលប្រទេសចុះកិច្ចសន្យាទាំងអស់ចាត់តាំងឡើង ចាត់ទុកជាអ្នកមានសមត្ថភាពក្នុងការអនុវត្តតួនាទីជាប្រធានអគ្គស្នងការទទួលបន្ទុកសម្បត្តិវប្បធម៌។ តាមគំនិតផ្តួចផ្តើមរបស់លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ បញ្ជីឈ្មោះនឹងត្រូវគេកែប្រែដោយទៀងទាត់ ដោយឈរលើមូលដ្ឋាននៃសំណើដែលបណ្តាប្រទេសចុះកិច្ចសន្យាលើកឡើង ។

### មាត្រា២: អង្គការត្រួតពិនិត្យ

បន្ទាប់ពីពេលដែលប្រទេសចុះកិច្ចសន្យាណាមួយ មានជាប់ទាក់ទិនក្នុងវិវាទប្រដាប់អាវុធភ្លាម ដូចសេចក្តីដែលបានចែងក្នុងមាត្រា១៨ នៃអនុសញ្ញា:

ក- ប្រទេសនោះ ត្រូវតែងតាំងតំណាងម្នាក់អោយទទួលខុសត្រូវខាងការងារសម្បត្តិវប្បធម៌ដែលស្ថិតនៅក្នុងដែនដីរបស់ខ្លួន។ ប្រសិនបើប្រទេសនោះបានចូលទៅកាន់កាប់ប្រទេសមួយផ្សេងទៀត ប្រទេសនោះត្រូវតែងតាំងអ្នកតំណាងពិសេសម្នាក់ អោយទទួលខុសត្រូវសម្បត្តិវប្បធម៌ ដែលស្ថិតនៅក្នុងដែនដីរបស់ប្រទេសមួយទៀតនោះ ។

ខ- អាជ្ញាធរការពារ ដែលជាតំណាងភាគីនីមួយៗដែលមានជំលោះជាមួយប្រទេសចុះកិច្ចសន្យា ត្រូវតែងតាំងគណៈប្រតិភូផ្លូវការទៅកាន់ប្រទេសខាងក្រោយនេះ ដោយអនុលោមតាមមាត្រា៣ ខាងក្រោម

គ- ប្រធានអគ្គស្នងការទទួលបន្ទុកសម្បត្តិវប្បធម៌ នឹងត្រូវគេតែងតាំងអោយទៅកាន់ប្រទេសចុះកិច្ចសន្យានោះ អនុលោមតាមមាត្រា៤ ខាងក្រោមនេះ ។

## មាត្រា៣៖ ការតែងតាំងគណៈប្រតិភូរបស់អាជ្ញាធរការពារ

អាជ្ញាធរការពារ ត្រូវតែងតាំងគណៈប្រតិភូរបស់ខ្លួន ដែលត្រូវបានជ្រើសរើសយកពីក្នុងសមាជិកបុគ្គលិកការទូត ឬស្ថានកុងស៊ុល ឬបុគ្គលដទៃទៀត ដោយមានការយល់ព្រមពីសំណាក់ភាគីដែលគណៈប្រតិភូនេះនឹងត្រូវបានគេទទួលស្គាល់ ។

## មាត្រា៤៖ ការតែងតាំងប្រធានអគ្គស្នងការ

១- ប្រធានអគ្គស្នងការទទួលបន្ទុកការងារសម្បត្តិវប្បធម៌ នឹងត្រូវគេជ្រើសរើសពីក្នុងបញ្ជីអន្តរជាតិនៃឈ្មោះបុគ្គល តាមរយៈកិច្ចព្រមព្រៀងរួម រវាងភាគីដែលប្រធានអគ្គស្នងការរូបនោះនឹងត្រូវគេទទួលស្គាល់ ជាមួយនិងអាជ្ញាធរការពារដែលធ្វើសកម្មភាពតំណាងអោយបណ្តាភាគីបដិបក្ខ ។

២- ប្រសិនបើភាគីទាំងនោះពុំអាចឈានដល់កិច្ចព្រមព្រៀងបានទេ ក្នុងរយៈពេលពាសប្តាហ៍ គិតចាប់ពីពេលចាប់ផ្តើមការពិភាក្សាលើចំនុចនេះ ភាគីទាំងនោះត្រូវស្នើសុំដល់ប្រធានតុលាការអន្តរជាតិអោយជួយតែងតាំងប្រធានអគ្គស្នងការ ហើយមន្ត្រីរូបនោះនឹងពុំទាន់ចូលកាន់តំណែងឡើយ រហូតទាល់តែភាគីដែលនឹងត្រូវទទួលស្គាល់រូបលោក បានយល់ព្រមជាផ្លូវការទទួលយកការតែងតាំងនោះ ។

## មាត្រា៥៖ តួនាទីរបស់គណៈប្រតិភូ

គណៈប្រតិភូរបស់អាជ្ញាធរការពារ ត្រូវកត់ត្រានូវការរំលោភលើអនុសញ្ញា ស៊ើបអង្កេតដោយមានការទទួលស្គាល់ពីសំណាក់ភាគីដែលបានទទួលស្គាល់ខ្លួន នូវសភាពការណ៍ដែលគេបានឃើញ ។ គណៈប្រតិភូនេះក៏ត្រូវដោះស្រាយរាល់ការងារចំពោះមុខជាក់ស្តែងដទៃៗទៀតដែរ ដើម្បីធានាដល់ការបញ្ចប់សកម្មភាពរំលោភនានា និងប្រសិនបើចាំបាច់ ត្រូវផ្តល់ពត៌មានដល់លោកប្រធានអគ្គស្នងការស្តីពីការរំលោភទាំងនេះ ។ គណៈប្រតិភូត្រូវផ្តល់ពត៌មានជានិច្ចជាកាលដល់លោកប្រធានអគ្គស្នងការ ស្តីអំពីសកម្មភាពរបស់ខ្លួន ។

## មាត្រា៦៖ តួនាទីរបស់ប្រធានអគ្គស្នងការ

១- ប្រធានអគ្គស្នងការទទួលបន្ទុកការងារសម្បត្តិវប្បធម៌ ត្រូវចាត់ចែងលើគ្រប់បញ្ហាដែលកើតឡើងទាក់ទិនដល់ការអនុវត្តអនុសញ្ញា ដោយសហការជាមួយតំណាងនៃភាគីដែលរូបលោកត្រូវបានគេទទួលស្គាល់ ព្រមទាំងជាមួយបណ្តាគណៈប្រតិភូពាក់ព័ន្ធផងដែរ ។

២- លោកប្រធានអគ្គស្នងការត្រូវមានអំណាចជាអ្នកសំរេច និងតែងតាំង ក្នុងរាល់ករណីដូចមានចែងបញ្ជាក់នៅក្នុងបទបញ្ជាសំរាប់ការអនុវត្តអនុសញ្ញានេះ ។

៣- ដោយមានការយល់ព្រមពីសំណាក់ភាគីដែលទទួលស្គាល់រូបលោក លោកប្រធានអគ្គស្នងការនឹងមានសិទ្ធិបង្គាប់អោយមានការស៊ើបអង្កេត ឬក៏ធ្វើការស៊ើបអង្កេតនោះដោយខ្លួនលោកផ្ទាល់ ។

៤- លោកប្រធានអគ្គស្នងការនឹងតំណាងអោយបណ្តាភាគី ឬតំណាងអោយបណ្តាអាជ្ញាធរការពាររបស់ភាគីក្នុងជំលោះ ធ្វើរាល់សកម្មភាពដែលលោកចាត់ទុកជាការមានប្រយោជន៏ដល់ការអនុវត្តអនុសញ្ញា ។

៥- លោកប្រធានអគ្គស្នងការត្រូវធ្វើរបាយការណ៏ ដែលអាចមានលក្ខណៈចាំបាច់ស្តីអំពីការអនុវត្តអនុសញ្ញា ហើយផ្សព្វផ្សាយរបាយការណ៏នោះដល់ប្រទេសទាំងឡាយដែលទាក់ទិន និងដល់អាជ្ញាធរការពារ ។ លោកប្រធានអគ្គស្នងការត្រូវធ្វើរបាយការណ៏ទាំងនោះ ជូនលោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ដែលពីក្នុងរបាយការណ៏នោះ លោកអគ្គនាយក អាចដកស្រង់យកទៅប្រើប្រាស់បានតែពតិមានខាងបច្ចេកទេសតែប៉ុណ្ណោះ ។

៦- ប្រសិនបើគ្មានអាជ្ញាធរការពារទេ ប្រធានអគ្គស្នងការនឹងអនុវត្តតួនាទីជាអាជ្ញាធរការពារ ដូចសេចក្តីដែលបានចែងនៅក្នុងមាត្រា២១ និង២២ នៃអនុសញ្ញា ។

## មាត្រា៧: អ្នកអធិការ និងអ្នកឯកទេស

១- ពេលណាដែលលោកប្រធានអគ្គស្នងការទទួលបន្ទុកការងារសម្បត្តិវប្បធម៌ យល់ថាចាំបាច់ដោយយោលទៅតាមសំណូមពររបស់គណៈប្រតិភូពាក់ព័ន្ធ ឬបន្ទាប់ពីការពិគ្រោះយោបល់ជាមួយប្រតិភូទាំងនោះរួចមក លោកប្រធានអគ្គស្នងការត្រូវលើកសំណើសុំ ដោយមានការយល់ព្រមពីភាគីដែលទទួលស្គាល់រូបលោកផង អោយមានអធិការមួយនាក់សំរាប់ការងារសម្បត្តិវប្បធម៌ ដើម្បីបំពេញបេសកកម្មពិសេសណាមួយ ។ លោកអធិការរូបនោះនឹងទទួលខុសត្រូវតែចំពោះលោកប្រធានអគ្គស្នងការម្នាក់គត់ ។

២- លោកប្រធានអគ្គស្នងការ គណៈប្រតិភូ និងលោកអធិការ អាចពឹងពាក់ទៅលើជំនួយពីសំណាក់បណ្តាអ្នកឯកទេស ដែលអ្នកឯកទេសនោះក៏ត្រូវតែបានគេស្នើតែងតាំង និងបានទទួលការយល់ព្រមទទួលស្គាល់ផងដែរពីសំណាក់ភាគីដូចបាននិយាយយោងនៅក្នុងកថាខ័ណ្ឌមុននេះ ។

## មាត្រា៨: ការបំពេញបេសកកម្មត្រួតពិនិត្យ

ប្រធានអគ្គស្នងការទទួលបន្ទុកការងារសម្បត្តិវប្បធម៌ គណៈប្រតិភូរបស់អាជ្ញាធរការពារ អ្នកអធិការ និងអ្នកឯកទេស នឹងមិនធ្វើអ្វីអោយលើសពីអាណត្តិរបស់ខ្លួនទេ ទោះក្នុងករណីណាក៏ដោយ ។ ជាពិសេស ពួកគេត្រូវយកចិត្តទុកដាក់ដល់សេចក្តីត្រូវការផ្នែកសន្តិសុខរបស់ប្រទេសចុះកិច្ចសន្យា ដែលខ្លួនកំពុង

បំពេញបេសកកម្មនៅទីនោះ ហើយត្រូវធ្វើសកម្មភាពគ្រប់កាលៈទេសៈទាំងអស់ស្របទៅតាមស្ថានការចាំបាច់នៃស្ថានការណ៍សឹក ដូចដែលប្រទេសចុះកិច្ចសន្យាចង្អុលបង្ហាញ ។

## មាត្រា៩: អ្នកជំនួសអាជ្ញាធរការពារ

ប្រសិនបើភាគីមួយក្នុងជំលោះពុំបានទទួលផលប្រយោជន៍ ឬត្រូវគេទប់ស្កាត់មិនអោយទទួលប្រយោជន៍ពីសកម្មភាពរបស់អាជ្ញាធរការពារ ប្រទេសអព្យាក្រឹតមួយអាចត្រូវគេសុំអោយមានតួនាទី ជាអាជ្ញាធរការពារ ដែលមានភារកិច្ចតែងតាំងប្រធានអគ្គស្នងការទទួលបន្ទុកការងារសម្បត្តិវប្បធម៌ ស្របទៅតាមបែបបទដូចមានចែងនៅក្នុងមាត្រា៤ពីខាងលើ ។ ប្រធានអគ្គស្នងការដែលត្រូវបានគេតែងតាំងឡើងនេះបើចាំបាច់ នឹងប្រគល់ជូនលោកអធិការ នូវតួនាទីជាប្រតិភូនៃអាជ្ញាធរការពារ ដូចសេចក្តីដែលបានចែងកំណត់នៅក្នុងបទបញ្ជានេះ ។

## មាត្រា១០: ការចំណាយ

ការទូទាត់ និងការចំណាយរបស់ប្រធានអគ្គស្នងការទទួលបន្ទុកការងារសម្បត្តិវប្បធម៌ អ្នកអធិការ និងអ្នកឯកទេស ត្រូវរ៉ាប់រងដោយប្រទេសដែលគេកំពុងបំពេញភារកិច្ច ។ ការទូទាត់ និងការចំណាយទៅលើគណៈប្រតិភូនៃអាជ្ញាធរការពារ នឹងអាស្រ័យដោយការព្រមព្រៀងរវាងប្រទេស និងអាជ្ញាធរទាំងនោះ ដោយឈរនៅលើទស្សនៈនៃការការពារផលប្រយោជន៍រួមគ្នា ។

# ជំពូកទី២

# ការការពារពិសេស

## មាត្រា១១: ជំរករក្សាសម្បត្តិវប្បធម៌ជាបន្ទាន់

១- ក្នុងគ្រាមានអធិករណ៍ប្រដាប់អាវុធ ប្រសិនបើប្រទេសចុះកិច្ចសន្យាណាមួយ ជួបប្រទះស្ថានភាពដែលពុំបានព្រៀងទុកជាមុនក្នុងការបង្កើតទីកន្លែងរក្សាសម្បត្តិវប្បធម៌ ហើយមានបំណងដាក់ទីកន្លែងនោះអោយស្ថិតនៅក្រោមការការពារពិសេស ប្រទេសនោះត្រូវទាក់ទងបញ្ហានេះជាមួយលោកប្រធានអគ្គស្នងការ ដែលប្រទេសនោះបានទទួលស្គាល់ ។

២- បើសិនជា លោកប្រធានអគ្គស្នងការយល់ថា វិធានការបែបនេះសមស្របទៅនឹងស្ថានការណ៍ហើយក៏ដោយសារសារសំខាន់នៃសម្បត្តិវប្បធម៌ត្រូវការពារ ដែលមាននៅក្នុងទីរក្សាជាបន្ទាន់នោះ លោកអាចអនុញ្ញាតិអោយប្រទេសចុះកិច្ចសន្យានោះដាក់បង្ហាញនៅនឹងកន្លែងរក្សានោះ នូវផ្លាកសញ្ញាដូចមានពណ៌នាក្នុងមាត្រា១៦នៃអនុសញ្ញា ។ ប្រធានអគ្គស្នងការត្រូវផ្សព្វផ្សាយសេចក្តីសំរេចចិត្តរបស់លោក

ដោយគ្មានបង្អង់ដល់បណ្តាប្រតិភូរបស់អាជ្ញាធរការពារដែលទាក់ទិន ប៉ុន្តែប្រតិភូនីមួយៗ ក្នុងចំណោមប្រតិភូទាំងនេះ ក្នុងកំឡុងកំណត់៣០ថ្ងៃ ក៏អាចចេញបញ្ជាអោយដកផ្លាកសញ្ញានោះចេញជាបន្ទាន់បានដែរ ។

៣- ជាបន្ទាន់ បន្ទាប់ពីបណ្តាប្រតិភូបានចុះហត្ថលេខាព្រមព្រៀងរបស់ខ្លួន ឬបើក្នុងរយៈពេល៣០ថ្ងៃ គ្មានប្រតិភូដែលពាក់ព័ន្ធណាមួយសំដែងការជំទាស់ទេនោះ និងប្រសិនបើតាមទស្សនៈរបស់ប្រធានអគ្គស្នងការ ទីជំរកនោះបានបំពេញតាមល័ក្ខខ័ណ្ឌដូចមានចែងនៅក្នុងមាត្រា៨ នៃអនុសញ្ញា លោកប្រធានអគ្គស្នងការត្រូវលើកសំណើជូនទៅលោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ អោយបញ្ចូលទីជំរកនោះបញ្ចូលទៅក្នុងបញ្ជីនៃសម្បត្តិវប្បធម៌ដែលស្ថិតនៅក្រោមការការពារពិសេស ។

## មាត្រា១២: ការចុះបញ្ជីអន្តរជាតិនៃសម្បត្តិវប្បធម៌ដែលដាក់អោយស្ថិតនៅក្រោមការការពារពិសេស

១- គេនឹងរៀបចំបញ្ជីអន្តរជាតិមួយស្តីអំពី "សម្បត្តិវប្បធម៌ដែលត្រូវដាក់អោយស្ថិតនៅក្រោមការការពារពិសេស" ។

២- លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ត្រូវរក្សាទុកបញ្ជីនោះ ។ លោកត្រូវបញ្ជូនច្បាប់ចំលងនៃបញ្ជីនោះ ជូនទៅលោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ និងជូនទៅបណ្តាប្រទេសចុះកិច្ចសន្យា ។

៣- បញ្ជីនោះនឹងមានច្រើនជំពូក ហើយជំពូកនីមួយៗត្រូវចុះនូវពត៌មានរបស់ប្រទេសចុះកិច្ចសន្យានីមួយៗ ។ ជំពូកទាំងនោះត្រូវចែកជាពាផ្នែកទៀត ដែលផ្នែកនីមួយៗមានចំណងជើងថាៈ ជំរករក្សាសម្បត្តិវប្បធម៌ មជ្ឈមណ្ឌលដែលមានកេរ្តិ៍តំណែលវប្បធម៌ និងអចលនសម្បត្តិវប្បធម៌ដទៃទៀត ។ លោកអគ្គនាយកនឹងកំណត់ថា តើខ្លឹមសារលំអិតអ្វីខ្លះដែលនឹងត្រូវរៀបរាប់នៅក្នុងជំពូកនីមួយៗនោះ ។

## មាត្រា១៣: សំណើសំរាប់ការចុះបញ្ជី

១- ប្រទេសចុះកិច្ចសន្យានីមួយៗ អាចដាក់ជូនលោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ នូវពាក្យសុំបញ្ចូលទៅក្នុងបញ្ជី នូវទីជំរករក្សាសម្បត្តិវប្បធម៌ មជ្ឈមណ្ឌលដែលមានមរតកវប្បធម៌ ឬអចលនសម្បត្តិវប្បធម៌ដទៃទៀត ដែលមាននៅក្នុងដែនដីរបស់ខ្លួន ។ ពាក្យសុំបែបនេះត្រូវរួមមានការពិពណ៌នាអំពីទីកន្លែងរបស់សម្បត្តិវប្បធម៌នោះតាំងនៅ ហើយនិងមានបញ្ជាក់ថា សម្បត្តិវប្បធម៌នោះមានល័ក្ខខ័ណ្ឌសមស្របទៅតាមប្រការដែលមានចែងនៅក្នុងមាត្រា៨ នៃអនុសញ្ញា ។

២- ក្នុងករណីមានការចូលកាន់កាប់ទឹកដី ប្រទេសដែលចូលកាន់កាប់ ត្រូវមានសមត្ថកិច្ចធ្វើពាក្យសុំនេះ ។

៣- លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ដោយគ្មានបង្អង់ ត្រូវធ្វើពាក្យសុំចុះបញ្ជី ទៅដល់ប្រទេសចុះកិច្ចសន្យានីមួយៗ ។

## មាត្រា១៤: ការជំទាស់

១- ប្រទេសចុះកិច្ចសន្យានីមួយៗអាចតាមរយៈលិខិត ផ្ញើជូនទៅលោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រនិងវប្បធម៌ នៃសហប្រជាជាតិ ដើម្បីធ្វើការជំទាស់បដិសេធចំពោះការចុះបញ្ជីនៃសម្បត្តិវប្បធម៌ ។ លោកអគ្គនាយក ត្រូវតែបានទទួលលិខិតថ្លែងការជំទាស់នោះក្នុងអំឡុងពេល៤ខែ គិតចាប់ពីថ្ងៃដែលលោកបានផ្សព្វផ្សាយពាក្យស្នើសុំចុះបញ្ជី ។

២- រាល់ការជំទាស់ទាំងឡាយ ត្រូវប្រកាសបញ្ជាក់ពីមូលហេតុដែលនាំអោយមានការជំទាស់ ហើយចំនុចដែលអាចជាបុព្វហេតុជំទាស់បាននោះគឺ:

ក- សម្បត្តិនោះពុំមែនជាសម្បត្តិវប្បធម៌

ខ- សម្បត្តិនោះគ្មានលក្ខណសម្បត្តិស្របទៅនឹងល័ក្ខខ័ណ្ឌដូចមានចែងនៅក្នុងមាត្រា៨ នៃអនុសញ្ញាឡើយ ។

៣- លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ដោយគ្មានបង្អង់នឹងផ្ញើលិខិតជំទាស់មួយច្បាប់ទៅប្រទេសចុះកិច្ចសន្យានីមួយៗ ។ ប្រសិនបើចាំបាច់ លោកនឹងស្នើសុំយោបល់ពីសំណាក់គណៈកម្មការអន្តរជាតិទទួលបន្ទុកប្រាង្គប្រាសាទ លានដ្ឋានប្រវត្តិសាស្ត្រនិងសិល្បៈ និងកិច្ចការកំណាយបុរាណវត្ថុ ហើយនិង បើសិនលោកគិតថាសមស្រប គឺពីសំណាក់អង្គការ ឬបុគ្គលមានសមត្ថកិច្ចដទៃទៀតផងដែរ ។

៤- លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ឬប្រទេសដែលធ្វើសំណើចុះបញ្ជី ត្រូវបំភ្លឺយ៉ាងណាដើម្បីធ្វើអោយប្រទេសចុះកិច្ចសន្យាដែលបានផ្ញើលិខិតសុំជំទាស់នោះ យល់ថាចាំបាច់ត្រូវលុបចោលការជំទាស់នោះវិញ ។

៥- ប្រសិនបើប្រទេសចុះកិច្ចសន្យាមួយ ដែលបានដាក់ពាក្យសុំចុះបញ្ជីនៅពេលប្រទេសខ្លួនមានសន្តិភាព ហើយស្រាប់តែចូលប្រឡូកទៅក្នុងវិវាទប្រដាប់អាវុធមួយ មុនការចុះទៅក្នុងបញ្ជីនូវសម្បត្តិវប្បធម៌ដែលគេបានស្នើសុំនោះ សម្បត្តិដែលមានពាក់ព័ន្ធនោះនឹងត្រូវបានបញ្ចូលភ្លាម និងជាបណ្តោះអាសន្នទៅក្នុង

បញ្ជី ដោយលោកអគ្គនាយក នៅក្នុងពេលរង់ចាំការបញ្ជាក់បន្ថែមអំពីការដែលត្រូវដកចេញ ឬលុបចោលទៅវិញនូវសំណើជំទាស់ណាមួយ ដែលអាចនឹង ឬដែលបានត្រូវគេធ្វើឡើងនោះ ។

៦- បើសិនជាក្នុងរយះពេល៦ខែ គិតចាប់ពីកាលបរិច្ឆេទដែលគេទទួលលិខិតជំទាស់ លោកអគ្គនាយកពុំបានទទួលពីប្រទេសដែលសុំជំទាស់នូវលិខិតលុបចោលការជំទាស់ទេនោះ ប្រទេសដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីអាចធ្វើសំណើអោយមានការសំរេចនៃអាជ្ញាកណ្តាល ស្របទៅតាមបែបបទដូចមានចែងនៅក្នុងកថាខ័ណ្ឌខាងក្រោយនេះ ។

៧- សំណើសុំអោយមានការសំរេចពីអាជ្ញាកណ្តាលពុំអាចធ្វើឡើងលើសពីរយះពេល១ឆ្នាំ បន្ទាប់ពីលោកអគ្គនាយកបានទទួលលិខិតជំទាស់ឡើយ ។ ប្រទេសនីមួយៗ ក្នុងចំណោមប្រទេសទាំងពីរដែលមានទំនាស់នឹងគ្នា ត្រូវតែងតាំងអាជ្ញាកណ្តាលម្នាក់មួយ ។ កាលណាមានការជំទាស់លើសពីមួយធ្វើឡើងប្រឆាំងសំណើសុំចុះបញ្ជីមួយ បណ្តាប្រទេសដែលសុំជំទាស់នឹងព្រមព្រៀងគ្នាតែងតាំងអាជ្ញាកណ្តាលតែមួយនាក់គត់ ។ អាជ្ញាកណ្តាលទាំងពីររូប នឹងជ្រើសរើសប្រធានអាជ្ញាកណ្តាលម្នាក់ពីក្នុងបញ្ជីអន្តរជាតិដែលបានចែងកំណត់នៅក្នុងមាត្រា១នៃបទបញ្ជានេះ ។ ប្រសិនបើអាជ្ញាកណ្តាលទាំងនេះពុំអាចព្រមព្រៀងគ្នាលើការជ្រើសរើសរបស់គេទេនោះ គេនឹងស្នើដល់ប្រធានតុលាការអន្តរជាតិអោយជួយតែងតាំងប្រធានអាជ្ញាកណ្តាល ដែលគេពុំចាំបាច់ជ្រើសរើសចេញពីក្នុងបញ្ជីអន្តរជាតិនោះទេ ។ តុលាការកាត់ក្តីដែលបង្កើតនេះនឹងបង្កើតវិធីធ្វើការងារផ្ទាល់របស់គេ ។ តុលាការនេះនឹងដាក់ចេញនូវសេចក្តីសំរេចដោយបិទផ្លូវតវ៉ាទាំងអស់ ។

៨- ប្រទេសចុះកិច្ចសន្យានីមួយៗអាចប្រកាស នៅពេលកើតមានទំនាស់ហើយដែលប្រទេសខ្លួន គឺជាភាគីមួយដែរនោះ ថាខ្លួនពុំមានបំណងអនុវត្តវិធីធ្វើការងារដើម្បីដំណើរការកាត់ក្តីដូចមានចែងក្នុងកថាខ័ណ្ឌខាងលើនេះទេ ។ ក្នុងករណីបែបនេះ ការជំទាស់ចំពោះពាក្យសុំចុះបញ្ជី នឹងត្រូវលោកអគ្គនាយកបញ្ជូនទៅគ្រប់ប្រទេសចុះកិច្ចសន្យាទាំងអស់ ។ គេនឹងយល់ព្រមទទួលយកសំណើជំទាស់លុះត្រាតែមានចំនួនពីរភាគបីនៃប្រទេសចុះកិច្ចសន្យាសំរេចចិត្តដូច្នេះតាមរយះការបោះឆ្នោត ។ ការបោះឆ្នោតនឹងប្រព្រឹត្តទៅតាមរយះលិខិតឆ្លើយឆ្លង លើកលែងតែលោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ យល់ថាជាការចាំបាច់ត្រូវកោះអញ្ជើញអោយមានការប្រជុំ ដែលជាសិទ្ធិដែលបានផ្តល់ជូនលោក ដូចសេចក្តីមានចែងនៅក្នុងមាត្រា២៧ នៃអនុសញ្ញា ។ ប្រសិនបើលោកអគ្គនាយកសំរេចធ្វើការបោះឆ្នោតដោយលិខិតឆ្លើយឆ្លង លោកនឹងស្នើសុំអោយបណ្តាប្រទេសចុះកិច្ចសន្យាផ្ញើឆ្នោតរបស់គេជា

លិខិតផ្លូវការមានបោះត្រា ក្នុងអំឡុងពេល៦ខែ គិតចាប់ពីថ្ងៃដែលប្រទេសទាំងនោះបានទទួលលិខិតស្នើអោយបោះឆ្នោត។

## មាត្រា១៥: ការចុះបញ្ជី

១- លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ត្រូវផ្តល់អោយមានការបញ្ចូលក្នុងបញ្ជី តាមលេខរៀងត្រឹមត្រូវ នូវវត្ថុនីមួយៗនៃសម្បត្តិវប្បធម៌ដែលត្រូវបានគេស្នើសុំបញ្ចូលវត្ថុទាំងនោះទៅក្នុងបញ្ជី អោយតែលោកពុំបានទទួលការជំទាស់ណាមួយ ក្នុងរយៈពេលកំណត់ដូចមានចែងនៅក្នុងកថាខ័ណ្ឌទី១នៃមាត្រា១៤។

២- បើសិនជាមានសំណើជំទាស់ និងដោយគ្មានការលំអៀងចំពោះប្រការដែលមានចែងនៅក្នុងកថាខ័ណ្ឌទី៥នៃមាត្រា១៤ លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិនឹងបញ្ចូលសម្បត្តិវប្បធម៌ដែលគេស្នើនោះទៅក្នុងបញ្ជី តែក្នុងករណីណាដែលពាក្យសុំជំទាស់នោះត្រូវបានគេលុបចោលវិញ ឬពាក្យសុំជំទាស់នោះពុំបានទទួលការយល់ព្រម ពីព្រោះតែដំណើរការដូចបានរៀបរាប់នៅក្នុងកថាខ័ណ្ឌទី៧ ឬទី៨ នៃមាត្រា១៤។

៣- កាលណាករណីនៅក្នុងកថាខ័ណ្ឌទី៣ នៃមាត្រា១១ បានកើតមាន លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ត្រូវបញ្ចូលសម្បត្តិវប្បធម៌នោះទៅក្នុងបញ្ជី ប្រសិនបើប្រធានអគ្គស្នងការទទួលបន្ទុកការងារសម្បត្តិវប្បធម៌ស្នើសុំ។

៤- លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ត្រូវបញ្ជូនដោយគ្មានបង្អង់ ដល់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ដល់បណ្តាប្រទេសចុះកិច្ចសន្យា និងយោងតាមសំណើរបស់ប្រទេសដែលដាក់ពាក្យសុំចុះបញ្ជី បញ្ជូនទៅប្រទេសដទៃទៀតដូចមានអធិប្បាយនៅក្នុងមាត្រា៣០ និង៣២ នៃអនុសញ្ញា នូវច្បាប់ចំលងបញ្ជាក់មួយស្តីពីការបញ្ចូលសម្បត្តិវប្បធម៌នីមួយៗទៅក្នុងបញ្ជី។ ការចូលទៅក្នុងបញ្ជី នឹងមានអនុភាពក្រោយ៣០ថ្ងៃ បន្ទាប់ពីការបញ្ជូនច្បាប់ចំលងទាំងនោះទៅគ្រប់ទីកន្លែង។

## មាត្រា១៦: ការលុបចោលសំណើសុំចុះបញ្ជី

១- លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ នឹងលុបចោលការចុះបញ្ជីនូវសម្បត្តិវប្បធម៌ណាមួយ:

ក- តាមសំណើរបស់ប្រទេសចុះកិច្ចសន្យាដែលសម្បត្តិវប្បធម៌នោះតាំងនៅ

ខ- ប្រសិនបើប្រទេសចុះកិច្ចសន្យាដែលស្នើសុំអោយមានការចុះបញ្ជី បានប្រកាសបដិសេធលុបចោលអនុសញ្ញាវិញ និងនៅពេលដែលការប្រកាសបដិសេធវិញនោះបានចូលជាធរមានហើយ

គ- ក្នុងករណីពិសេសដូចមានចែងក្នុងកថាខ័ណ្ឌទី៥ មាត្រា១៤ ពេលដែលពាក្យសុំជំទាស់ បានទទួលការយល់ព្រមដោយឆ្លងកាត់ដំណើរការដូចមានចែងក្នុងកថាខ័ណ្ឌទី៧ ឬទី៨ នៃមាត្រា១៤។

២- លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ត្រូវផ្ញើដោយគ្មានបង្អង់ជូនទៅលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ និងជូនដល់ប្រទេសទាំងអស់ដែលបានទទួលលិខិតចំលងមួយច្បាប់ស្តីពីការបញ្ចូលទៅក្នុងបញ្ជី នូវលិខិតបញ្ជាក់មួយច្បាប់ស្តីពីការលុបចោលការចុះបញ្ជីនោះវិញ។ ការលុបចោលនឹងចូលជាធរមានក្រោយ៣០ថ្ងៃ បន្ទាប់ពីការចែកចាយលិខិតទាំងនោះទៅកាន់គ្រប់ទីកន្លែង។

## ជំពូកទី៣

## ការដឹកជញ្ជូនសម្បត្តិវប្បធម៌

### មាត្រា១៧៖ បែបបទដើម្បីទទួលបានអភ័យឯកសិទ្ធិ

១- សំណើដូចមានចែងនៅក្នុងកថាខ័ណ្ឌទី១ មាត្រា១២ នៃអនុសញ្ញា នឹងត្រូវគេបញ្ជូនទៅលោកប្រធានអគ្គស្នងការទទួលបន្ទុកការងារសម្បត្តិវប្បធម៌។ សំណើនោះត្រូវបង្ហាញពីមូលហេតុដែលតំរូវអោយមានការផ្លាស់ប្តូរទីកន្លែងសម្បត្តិវប្បធម៌នោះ និងបញ្ជាក់នូវចំនួនប្រហាក់ប្រហែល និងអំពីសារសំខាន់នៃវត្ថុដែលត្រូវដឹកជញ្ជូន ទីកន្លែងបច្ចុប្បន្នរបស់វា ទីកន្លែងដែលគ្រោងនឹងបញ្ជូនវត្ថុនោះទៅទុកមធ្យោបាយដឹកជញ្ជូនដែលត្រូវប្រើ ផ្លូវដែលត្រូវឆ្លងកាត់ កាលបរិច្ឆេទសំរាប់ការដឹកជញ្ជូន និងពត៌មានទាក់ទិនដទៃទៀត។

២- ប្រសិនបើលោកប្រធានអគ្គស្នងការ បន្ទាប់ពីបានគិតពីកិរិតដែលយល់ថាសមស្រប យល់ថាការដឹកជញ្ជូនផ្លាស់ប្តូរទីកន្លែងនេះមានហេតុផលសមស្រប លោកនឹងពិគ្រោះយោបល់ជាមួយគណៈប្រតិភូនៃអាជ្ញាធរការពារដែលទាក់ទិន ទៅលើវិធានការដែលលើកឡើងសំរាប់អនុវត្តការងារដឹកជញ្ជូន។ បន្ទាប់ពីការពិគ្រោះយោបល់នោះមក លោកប្រធានអគ្គស្នងការត្រូវផ្តល់ពត៌មានដល់បណ្តាភាគីក្នុងជំលោះ អំពីការដឹកជញ្ជូន រួមទាំងពត៌មានសមស្របដទៃទៀតផងដែរ។

៣- លោកប្រធានអគ្គស្នងការត្រូវតែងតាំង អធិការម្នាក់ ឬច្រើននាក់ ដែលជាអ្នកធានាថាត្រូវដឹកជញ្ជូនតែវត្ថុដែលមានបញ្ជាក់ក្នុងសំណើ ហើយការដឹកជញ្ជូនត្រូវតែប្រព្រឹត្តទៅតាមទំរង់ការដែលបានព្រម

ព្រៀងរួចហើយ ហើយត្រូវមានភ្ជាប់ទាំងផ្លាកសញ្ញាផងដែរ ។ អធិការទាំងនេះនឹងត្រូវទៅតាមវត្ថុដឹកជញ្ជូននោះជាប់រហូត ទាល់តែវត្ថុនោះបានទៅដល់គោលដៅរបស់វា ។

## មាត្រា១៨: ការដឹកជញ្ជូនទៅក្រៅប្រទេស

ពេលដែលការដឹកនាំស្ថិតនៅក្រោមការការពារពិសេស ត្រូវបានប្រព្រឹត្តទៅពីប្រទេសមួយចូលទៅកាន់ដែនដីនៃប្រទេសមួយទៀត វានឹងត្រូវប្រព្រឹត្តទៅដោយមិនត្រឹមតែអនុលោមទៅតាមមាត្រា១២ នៃអនុសញ្ញា និងមាត្រា១៧ នៃបទបញ្ជានេះប៉ុណ្ណោះទេ តែត្រូវតែប្រព្រឹត្តទៅតាមចំណុចបន្ថែមដូចតទៅនេះ:

ក- ពេលដែលសម្បត្តិវប្បធម៌ស្ថិតនៅលើទឹកដីប្រទេសមួយផ្សេងទៀត ប្រទេសនោះនឹងក្លាយទៅជាកន្លែងទទួលថែរក្សាសម្បត្តិទាំងនោះ ហើយប្រទេសនោះត្រូវតែយកចិត្តទុកដាក់ថែទាំងយ៉ាងប្រុងប្រយ័ត្ននូវសម្បត្តិទាំងនោះ ហាក់បីដូចជាខ្លួនយកចិត្តទុកដាក់ថែរក្សាសម្បត្តិវប្បធម៌ដ៏មានតំលៃផ្ទាល់ខ្លួនដូច្នោះដែរ

ខ- ប្រទេសដែលទទួលថែរក្សា នឹងបញ្ជូនសម្បត្តិនោះសងមកវិញ តែនៅពេលបញ្ចប់ជំលោះ ហើយការបញ្ជូនត្រឡប់មកវិញនោះនឹងមានអនុភាពនៅរយៈពេល៦ខែ បន្ទាប់ពីកាលបរិច្ឆេទដែលគេស្នើឡើង

គ- ក្នុងរយៈពេលនៃប្រតិបត្តិការដឹកជញ្ជូនផ្សេងៗ និងនៅពេលដែលវាស្ថិតនៅលើដែនដីនៃប្រទេសមួយទៀត សម្បត្តិវប្បធម៌នឹងត្រូវបានរួចផុតពីគ្រប់ការប្រចាប់រឹបអូស និងពុំអាចត្រូវចាត់ចែង បែងចែកដោយអ្នកថែទាំ ឬដោយកន្លែងទទួលថែទាំសម្បត្តិនោះបានឡើយ ។ លើសពីនេះទៀត នៅពេលដែលសភាពការណ៍សន្តិសុខសំរាប់សម្បត្តិនោះតំរូវប្រទេសដែលទទួលថែរក្សា ដោយមានការយល់ព្រមពីអ្នកថែទាំផង អាចបញ្ជូនសម្បត្តិនោះទៅកាន់ដែនដីនៃប្រទេសទីបីទៀត ដោយត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចមានអធិប្បាយនៅក្នុងមាត្រានេះ

ឃ- សំណើសុំការការពារពិសេសត្រូវបញ្ជាក់អោយច្បាស់ថា ប្រទេសដែលគេបំរុងនឹងបញ្ជូនសម្បត្តិវប្បធម៌ទៅនោះ ពិតជាទទួលយកបញ្ញត្តិទាំងឡាយដែលបានចែងនៅក្នុងមាត្រានេះ ។

## មាត្រា១៩: ដែនដីដែលគេចូលទៅកាន់កាប់

នៅពេលណាដែលប្រទេសចុះកិច្ចសន្យាមួយ ចូលទៅកាន់កាប់ទឹកដីរបស់ប្រទេសចុះកិច្ចសន្យាមួយទៀត ហើយបានបញ្ជូនសម្បត្តិវប្បធម៌ទៅកាន់កន្លែងថែរក្សាដែលស្ថិតនៅទីណាមួយក្នុងទឹកដីនោះ ដោយពុំអាចអនុវត្តតាមបែបបទដូចមានចែងនៅក្នុងមាត្រា១៧ នៃបទបញ្ជានេះ ការដឹកជញ្ជូនផ្លាស់ប្តូរទីកន្លែង

នោះ នឹងពុំត្រូវគេចាត់ទុកថាជាការយកទៅធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយខុសច្បាប់ ដូចសេចក្តីដែលមានចែងនៅក្នុងមាត្រា៤នៃអនុសញ្ញាទេ ប្រសិនបើប្រធានអគ្គស្នងការទទួលបន្ទុកការងារសម្បត្តិវប្បធម៌ បានបញ្ជាក់ជាលាយល័ក្ខណ៍អក្សរ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយភ្នាក់ការពារថា ការដឹកជញ្ជូនប្តូរទីកន្លែងនេះ ប្រព្រឹត្តទៅក្រោមកាលៈទេសៈដ៏ចាំបាច់នោះ ។

## ជំពូកទី៥

## ផ្លាកសញ្ញាសំគាល់

### មាត្រា២០: ការលើកផ្លាកសញ្ញា

១- ការដាក់ភ្ជាប់នូវផ្លាកសញ្ញា ហើយនិងកំរិតនៃការបញ្ចេញអោយឃើញផ្លាកសញ្ញា នឹងត្រូវសំរេចដោយរដ្ឋអំណាចមានសមត្ថកិច្ចនៃប្រទេសចុះកិច្ចសន្យានីមួយៗ ។ គេអាចលើកបង្ហាញផ្លាកសញ្ញានៅលើទង់ ឬនៅលើប្រឡង់ដៃ ។ គេក៏អាចគូរវានៅលើវត្ថុអ្វីមួយ ឬបង្ហាញតាមទំរង់សមស្របដទៃទៀតបានដែរ ។

២- យ៉ាងណាក្តី ដោយពុំអោយច្រឡំទៅនឹងផ្លាកចំណាំដទៃទៀតដែលអាចមាន ផ្លាកសញ្ញានេះក្នុងករណីមានជំលោះប្រដាប់អាវុធ ឬក្នុងករណីដូចមានអធិប្បាយក្នុងមាត្រា១២ និង១៣ នៃអនុសញ្ញានឹងត្រូវបានគេដាក់បង្ហាញនៅលើយានដឹកជញ្ជូន ដើម្បីអោយគេអាចមើលវាឃើញច្បាស់ នៅពេលថ្ងៃពីលើអាកាសក៏ដូចជានៅនឹងដី ។ គេអាចមើលឃើញផ្លាកសញ្ញានៅនឹងដីដោយៈ

ក- ក្នុងគំលាតគ្នាទៀងទាត់ ដែលគ្រប់គ្រាន់ដើម្បីបង្ហាញយ៉ាងច្បាស់នូវបរិវេណ មជ្ឈមណ្ឌលដែលមានមរតកវប្បធម៌ស្ថិតក្រោមការការពារពិសេស

ខ- នាមាត់ច្រកចូលទៅកាន់អចលនសម្បត្តិវប្បធម៌ដទៃទៀត ដែលស្ថិតនៅក្រោមការការពារពិសេស ។

### មាត្រា២១: អត្តសញ្ញាណបណ្ណរបស់បុគ្គលិក

១- បុគ្គលដូចមានរៀបរាប់នៅក្នុងមាត្រា១៧ កថាខ័ណ្ឌទី២ ក និងគ នៃអនុសញ្ញា អាចពាក់ប្រឡង់ដៃដែលមានផ្លាកសញ្ញាដែលចារ និងបោះត្រាដោយរដ្ឋអំណាចមានសមត្ថកិច្ច ។

២- បុគ្គលបែបនេះអាចកាន់អត្តសញ្ញាណប័ណ្ណពិសេសដែលមានផ្លាកសញ្ញាសំគាល់ ។ អត្តសញ្ញាណប័ណ្ណនេះត្រូវអធិប្បាយយ៉ាងហោចណាស់គឺ គោត្តនាម និងនាម កាលបរិច្ឆេទកំណើត មុខងារឬឋានៈ និងតួនាទីរបស់អ្នកកាន់អត្តសញ្ញាណប័ណ្ណ ។ អត្តសញ្ញាណប័ណ្ណនេះនឹងមានបិទរូបថតរបស់ម្ចាស់អ្នកកាន់ រួម

ទាំងហត្ថលេខា ឬស្នាមផ្តិតម្រាមដៃ ឬទាំងពីរមុខ។ អត្តសញ្ញាណប័ណ្ណនេះត្រូវមានបោះត្រាផុសរបស់រដ្ឋអំណាចមានសមត្ថកិច្ច។

៣- ប្រទេសចុះកិច្ចសន្យានីមួយៗ នឹងបង្កើតនូវប្រភេទអត្តសញ្ញាណប័ណ្ណរបស់ប្រទេសខ្លួនស្របទៅតាមគំរូដែលភ្ជាប់ជាមួយទុកជាឧទាហរណ៍នៅក្នុងបទបញ្ជានេះ។ ប្រទេសចុះកិច្ចសន្យានីមួយៗនឹងផ្ញើអោយគ្នាទៅវិញទៅមកនូវគំរូអត្តសញ្ញាណប័ណ្ណដែលប្រទេសគេប្រើប្រាស់។ អត្តសញ្ញាណប័ណ្ណនឹងត្រូវធ្វើឡើងប្រសិនបើអាច យ៉ាងហោចណាស់ជាពីរច្បាប់ មួយច្បាប់ត្រូវរក្សាទុកដោយរដ្ឋអំណាច ដែលជាអ្នកចេញអត្តសញ្ញាណប័ណ្ណនេះ។

៤- បុគ្គលដូចពណ៌នាមកនេះ បើគ្មានមូលហេតុត្រឹមត្រូវតាមច្បាប់ ពុំអាចត្រូវគេដកហូតអត្តសញ្ញាណប័ណ្ណ ឬសិទ្ធិពាក់ប្រឡង់ដៃរបស់គេឡើយ។

**ពិធីសារ**

បណ្តាប្រទេសចុះកិច្ចសន្យា បានព្រមព្រៀងដូចតទៅ:

**១-**

១០- ប្រទេសចុះកិច្ចសន្យានីមួយៗ យល់ព្រមទប់ស្កាត់ការនាំចេញពីដែនដីរបស់ប្រទេសមួយដែលខ្លួនចូលទៅកាន់កាប់ក្នុងពេលមានវិវាទប្រដាប់អាវុធ នូវសម្បត្តិវប្បធម៌ដូចមានចែងនៅក្នុងមាត្រា១ នៃអនុសញ្ញាស្តីពីការការពារសម្បត្តិវប្បធម៌ក្នុងពេលមានជំលោះប្រដាប់អាវុធ ដែលបានចុះហត្ថលេខានៅទីក្រុងឡាអេ នាថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥៤។

២- ប្រទេសចុះកិច្ចសន្យានីមួយៗ យល់ព្រមថែរក្សាការពារសម្បត្តិវប្បធម៌ទាំងឡាយណាដែលគេបាននាំចូលមកក្នុងដែនដីរបស់ខ្លួនដោយផ្ទាល់ ឬដោយប្រយោល ចេញពីដែនដីណាមួយដែលត្រូវគេចូលទៅកាន់កាប់។ ការថែរក្សានេះនឹងត្រូវធ្វើឡើងដោយស្វ័យប្រវត្តិបន្ទាប់ពីសម្បត្តិវប្បធម៌នោះត្រូវបានគេនាំចូលមក ឬបើពុំដូច្នោះទេ ក៏តាមសំណើរបស់រដ្ឋអំណាចនៃប្រទេសម្ចាស់ទ្រព្យនេះដែរ។

៣- ប្រទេសចុះកិច្ចសន្យានីមួយៗយល់ព្រមសងទៅវិញ នៅពេលបញ្ចប់អរិភាព ដល់រដ្ឋអំណាចមានសមត្ថកិច្ចនៃទឹកដីដែលខ្លួនកាន់កាប់ពីមុន នូវសម្បត្តិវប្បធម៌ដែលស្ថិតនៅក្នុងដែនដីរបស់ខ្លួនប្រសិនបើសម្បត្តិនោះបានត្រូវនាំចេញមកពីក្នុងទឹកដីនោះ ដែលវាផ្ទុយទៅនឹងគោលការណ៍ដែលមានចែងនៅក្នុងកថាខ័ណ្ឌទី១។ សម្បត្តិដែលត្រូវបានគេនាំចេញពីក្នុងដែនដីដែលគេចូលទៅកាន់កាប់បែបនេះ ពុំអាចចាត់ទុកជាថ្នូរដើម្បីជួសជុលការបង់ខាតដោយសារសង្គ្រាមនោះឡើយ។

32

៤- ប្រទេសចុះកិច្ចសន្យា ដែលមានកាតព្វកិច្ចទប់ស្កាត់ការនាំចេញសម្បត្តិវប្បធម៌ក្នុងដែនដីដែលខ្លួនបានចូលទៅកាន់កាប់ ត្រូវទូទាត់សងទៅម្ចាស់ទ្រព្យណាដែលបានទិញសម្បត្តិនោះដោយសុចរិត នៅពេលដែលសម្បត្តិនោះត្រូវសងត្រឡប់ទៅម្ចាស់ដើមវិញ ស្របទៅតាមអត្ថន័យដូចមានចែងនៅក្នុងកថាខ័ណ្ឌមុននេះ ។

២~

៥- សម្បត្តិវប្បធម៌ដែលបាននាំចេញពីដែនដីនៃប្រទេសចុះកិច្ចសន្យាមួយ ហើយដែលបានទុកដាក់នៅក្នុងប្រទេសចុះកិច្ចសន្យាមួយទៀត ក្នុងគោលបំណងថែរក្សាការពារទ្រព្យនោះចៀសពីគ្រោះថ្នាក់ផ្សេងៗដែលបណ្តាលមកអំពីជំលោះប្រដាប់អាវុធ នឹងត្រូវបញ្ជូនត្រឡប់ទៅវិញដោយប្រទេសខាងក្រោយនេះទៅអោយរដ្ឋអំណាចមានសមត្ថកិច្ចនៃប្រទេសម្ចាស់ទ្រព្យនៅពេលបញ្ចប់អរិភាព ។

៣~

៦- ពិធីសារនេះនឹងចុះកាលបរិច្ឆេទថ្ងៃទី១៤ ឧសភា ឆ្នាំ១៩៥៤ ហើយរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៥៤ នឹងស្ថិតនៅជាចំហសំរាប់ការចុះហត្ថលេខាពីសំណាក់ប្រទេសទាំងឡាយ ដែលត្រូវបានអញ្ជើញអោយចូលរួមក្នុងសន្និសីទដែលប្រារព្ធធ្វើឡើងនៅទីក្រុងឡាអេ ពីថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៥៤ ដល់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥៤ ។

៧-

ក) ពិធីសារនេះនឹងត្រូវទទួលការផ្តល់សច្ចានុម័តពីសំណាក់ប្រទេសហត្ថលេខី ស្របទៅតាមរដ្ឋធម្មនុញ្ញរបស់ប្រទេសនីមួយៗទាំងនោះ ។

ខ) ឯកសារផ្លូវការនៃការផ្តល់សច្ចានុម័ត នឹងត្រូវបញ្ជូនដល់លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ។

៨- ចាប់តាំងពីថ្ងៃចូលជាធរមាន ពិធីសារនេះនឹងស្ថិតនៅជាចំហសំរាប់ការសុំចូលជាសមាជិក ពីសំណាក់ប្រទេសទាំងអស់ ដូចមានអធិប្បាយនៅក្នុងកថាខ័ណ្ឌទី៦ ដែលពុំទាន់បានចុះហត្ថលេខាលើឯកសារនេះព្រមទាំងប្រទេសដទៃទៀតដែលត្រូវអញ្ជើញអោយចូលជាសមាជិក ពីសំណាក់គណៈកម្មាធិការប្រតិបត្តិរបស់អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ។ ការសុំចូលជាសមាជិក នឹងត្រូវធ្វើឡើងដោយការផ្តល់ឯកសារផ្លូវការនៃការសុំចូលជាសមាជិកជូនចំពោះលោកអគ្គនាយក អង្គការ អប់រំ វិទ្យា-សាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ។

៩- បណ្ដាប្រទេសទាំងឡាយដូចបាននិយាយយោងនៅក្នុងកថាខ័ណ្ឌទី៦ និងទី៨ អាចប្រកាសក្នុងពេលចុះហត្ថលេខាផ្ដល់សច្ចានុម័ត ឬពេលចុះហត្ថលេខាសុំចូលជាសមាជិក ថាខ្លួននឹងមិនអនុវត្តតាមបញ្ញត្តិទាំងឡាយនៃផ្នែកទី**១** និងទី**២** នៃពិធីសារនេះបាន ។

១០-

ក) ពិធីសារនេះនឹងចូលជាធរមាននៅរយៈពេល៣ខែ បន្ទាប់ពីគេបានទទួលឯកសារផ្លូវការនៃការផ្ដល់សច្ចានុម័តចំនួន៥ច្បាប់ រួចមកនោះ ។

ខ) ចាប់ពីពេលនោះទៅ វានឹងចូលជាធរមានសំរាប់ប្រទេសចុះកិច្ចសន្យានីមួយៗនៅរយៈពេល៣ខែ បន្ទាប់ពីពេលដែលប្រទេសនោះផ្ដល់ឯកសារនៃការផ្ដល់សច្ចានុម័ត ឬឯកសារផ្លូវការនៃការសុំចូលជាសមាជិក ។

គ) ស្ថានភាពដូចមានចែងនៅក្នុងមាត្រា១៨ និង១៩ នៃអនុសញ្ញា ស្ដីពីការការពារសម្បត្តិវប្បធម៌ក្នុងគ្រាមានជំលោះប្រដាប់អាវុធ ដែលបានចុះហត្ថលេខានៅទីក្រុងឡាអេ ថ្ងៃទី១៤ ឧសភា ឆ្នាំ១៩៥៤ នឹងផ្ដល់អនុភាពភ្លាមដល់សច្ចានុម័ត និងពាក្យសុំចូលជាសមាជិកដែលស្នើឡើងដោយប្រទេសទាំងឡាយក្នុងជំលោះ ទាំងមុន ឬក្រោយការចាប់ផ្ដើមនៃជំលោះ ឬការចូលកាន់កាប់ទឹកដី ។ ក្នុងករណីបែបនេះ លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ត្រូវបញ្ជូនពត៌មានដូចមានចែងក្នុងកថាខ័ណ្ឌទី១៤ ដោយវិធីណាមួយយ៉ាងឆាប់រហ័សបំផុត ។

១១-

ក) ប្រទេសនីមួយៗដែលជាសមាជិកនៃពិធីសារនេះ នាពេលដែលពិធីសារចូលជាធរមាន ត្រូវចាត់គ្រប់វិធានការចាំបាច់នានាដើម្បីធានាការអនុវត្តអោយមានប្រសិទ្ធិភាព ក្នុងរយៈពេល ៦ខែ គិតចាប់ពីថ្ងៃពិធីសារចូលជាធរមាន ។

ខ) រយៈពេល៦ខែនេះ គឺគិតចាប់ពីថ្ងៃផ្ដល់ឯកសារផ្លូវការនៃការផ្ដល់សច្ចានុម័ត ឬការសុំចូលជាសមាជិក សំរាប់ប្រទេសណាដែលផ្ដល់ឯកសារផ្លូវការនៃការផ្ដល់សច្ចានុម័ត ឬ ឯកសារផ្លូវការនៃការសុំចូលជាសមាជិក ក្រោយពេលដែលពិធីសារចូលជាធរមានរួចមក ។

១២- ប្រទេសចុះកិច្ចសន្យានីមួយៗអាចប្រកាស ក្នុងពេលផ្ដល់សច្ចានុម័ត ឬក្នុងពេលសុំចូលជាសមាជិក ឬពេលណាមួយក៏បានបន្ទាប់ពីនោះ ដោយផ្ដល់ពត៌មានជូនចំពោះលោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ថាពិធីសារនេះនឹងត្រូវផ្សព្វផ្សាយនៅទូទាំងប្រទេស ឬទូទាំងដែន

ដីណាមួយដែលខ្លួនទទួលខុសត្រូវផ្នែកទំនាក់ទំនងអន្តរជាតិ ។ ការផ្តល់ពត៌មាននេះនឹងមានអនុភាពក្នុងរយៈ ពេល៣ខែ បន្ទាប់ពីពេលដែលលោកអគ្គនាយកបានទទួល ។

១៣-

ក) ប្រទេសចុះកិច្ចសន្យានីមួយៗ អាចប្រកាសបដិសេធលុបចោលពិធីសារនេះវិញបាន ដោយតាងនាមខ្លួនផ្ទាល់ ឬតាងនាមអោយដែនដីណាមួយដែលខ្លួនទទួលខុសត្រូវលើផ្នែកទំនាក់ទំនងអន្តរជាតិ ។

ខ) ការប្រកាសបដិសេធវិញនេះនឹងត្រូវធ្វើឡើងដោយឯកសារផ្លូវការ ជាលាយល័ក្ខណ៍អក្សរបញ្ជូនទៅលោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ។

គ) ការប្រកាសបដិសេធវិញ នឹងមានអនុភាពក្រោយរយៈពេលមួយឆ្នាំបន្ទាប់ពីគេបានទទួលឯកសារផ្លូវការប្រកាសបដិសេធនោះ ។ ទោះយ៉ាងណាក្តី ក្នុងពេលផុតកំណត់រយៈពេលនេះ ប្រសិនបើប្រទេសដែលប្រកាសបដិសេធ មានជាប់ទាក់ទិននៅក្នុងវិវាទប្រដាប់អាវុធណាមួយវិញនោះការប្រកាសបដិសេធនេះនឹងពុំបានទទួលប្រសិទ្ធិភាពទេ រហូតទាល់តែជំលោះនោះបានត្រូវបញ្ចប់ ឬរហូតទាល់តែប្រតិបត្តិការបញ្ជូនសម្បត្តិវប្បធម៌សងត្រឡប់ទៅវិញត្រូវបានបំពេញរួចរាល់សិន ទើបការប្រកាសបដិសេធនោះនឹងបានចូលជាធរមានជាក្រោយ ។

១៤- លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ត្រូវផ្តល់ពត៌មានដល់ប្រទេសទាំងឡាយដូចមានចែងនៅក្នុងកថាខ័ណ្ឌទី៦ និងទី៨ ព្រមទាំងជូនដល់អង្គការសហប្រជាជាតិផងដែរ ស្តីអំពីការផ្តល់ឯកសារផ្លូវការនៃការផ្តល់សច្ចានុម័ត ការសុំចូលជាសមាជិក ឬការទទួលស្គាល់ ដូចមានចែងនៅក្នុងកថាខ័ណ្ឌទី៧ ៨ និង១៥ ហើយនិងការផ្តល់ឯកសារផ្លូវការនៃការផ្តល់ពត៌មាន និងការប្រកាសបដិសេធវិញ ដូចមានចែងនៅក្នុងកថាខ័ណ្ឌទី១២ និង១៣ ។

១៥-

ក) ពិធីសារនេះអាចនឹងត្រូវកែសំរួលឡើងវិញ ប្រសិនបើមាន លើសពីមួយភាគបីនៃប្រទេសចុះកិច្ចសន្យាស្នើសុំអោយធ្វើវិសោធនកម្ម ។

ខ) លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ត្រូវកោះបើកសន្និសីទសំរាប់គោលបំណងនេះ ។

គ) វិសោធនកម្មនៃពិធីសារនេះនឹងចូលជាធរមានបាន លុះត្រាតែប្រទេសទាំងអស់ដែលចូលរួមក្នុងសន្និសីទ បានអនុម័តជាឯកច្ឆ័ន្ទ នឹងទទួលយកដោយភាគីនីមួយៗនៃប្រទេសចុះកិច្ចសន្យា ។

ឃ) ការទទួលយក ពីសំណាក់ប្រទេសចុះកិច្ចសន្យាទាំងអស់នូវវិសោធនកម្មលើពិធីសារនេះដែលបាន អនុម័តដោយសន្និសីទ ដូចមានរៀបរាប់នៅក្នុងអនុកថាខ័ណ្ឌ ខ និងគ នឹងទទួលបានអនុភាពដោយការ ផ្តល់ឯកសារផ្លូវការជូនទៅលោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ។

ង) បន្ទាប់ពីវិសោធនកម្មនៃពិធីសារចូលជាធរមានរួចមក គឺមានតែអត្ថបទនៃពិធីសារដែលបានធ្វើ វិសោធនកម្មនេះទេដែលនឹងស្ថិតនៅជាចំហសំរាប់ការផ្តល់សច្ចានុម័ត ឬការសុំចូលជាសមាជិក ។

អនុលោមទៅតាមមាត្រា១០២ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ពិធីសារនេះនឹងត្រូវចុះបញ្ជីនៅ លេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិ តាមសំណើរបស់លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ។

នៅក្នុងភក្តីភាព និងសមត្ថកិច្ចដ៏បរិបូរណ៍ ហត្ថលេខីទាំងអស់បានចុះហត្ថលេខាលើឯកសារពិធីសារនេះ ។

ធ្វើនៅទីក្រុងឡាអេ ថ្ងៃទី១៤ ឧសភា ឆ្នាំ១៩៥៤ ជាភាសាអង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ៉ុល ។ អត្ថបទទាំង ៤ភាសា មានតំលៃស្មើគ្នាតាមផ្លូវច្បាប់ ជាច្បាប់តែមួយគត់ដែលត្រូវតំកល់ទុកនៅនឹងបណ្ណ សារដ្ឋានរបស់អង្គការ អប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ និងបញ្ជាក់ថាច្បាប់ចំលង ត្រឹមត្រូវនឹងត្រូវចែកជូនដល់ប្រទេសទាំងអស់ ដូចមានអធិប្បាយនៅក្នុងកថាខ័ណ្ឌទី៦ និងទី៨ ព្រមទាំង ជូនទៅអង្គការសហប្រជាជាតិផងដែរ ។

## សេចក្តីសំរេច

### *សេចក្តីសំរេចទី១*

សន្និសីទសំដែងនូវសេចក្តីសង្ឃឹមថា អង្គការមានសមត្ថកិច្ចនានារបស់អង្គការសហប្រជាជាតិនឹងធ្វើការ សំរេចចិត្ត ក្នុងករណីកើតមានប្រតិបត្តិការយោធានៅក្នុងពេលអនុវត្តអនុសញ្ញា គឺតំរូវអោយកងយោធា ដែលកំពុងធ្វើសកម្មភាពប្រដាប់អាវុធទាំងនោះ ត្រូវតែគោរពអនុវត្តតាមមាត្រាបញ្ញត្តិទាំងឡាយរបស់ អនុសញ្ញា ។

### *សេចក្តីសំរេចទី២*

សន្និសីទសំដែងនូវសេចក្តីសង្ឃឹមថា ប្រទេសចុះកិច្ចសន្យានីមួយៗ ពេលក្លាយទៅជាសមាជិកអនុសញ្ញា គប្បីបង្កើតឡើង នៅក្នុងក្របខ័ណ្ឌនៃប្រព័ន្ធធម្មនុញ្ញនិងរដ្ឋាភិបាលរបស់ខ្លួននូវគណៈកម្មាធិការពិគ្រោះ យោបល់ជាតិមួយ ដែលរួមមានបុគ្គលល្បីឈ្មោះមួយចំនួន ជាឧទាហរណ៍មាន មន្ត្រីជាន់ខ្ពស់មួយចំនួននៃ អង្គការសេវាកម្មផ្នែកបុរាណវត្ថុ ផ្នែកសារមន្ទីរ ។ល ។ ប្រតិភូយោធាម្នាក់ ប្រតិភូក្រសួងការបរទេសម្នាក់

អ្នកឯកទេសច្បាប់អន្តរជាតិម្នាក់ និងសមាជិកមួយចំនួនទៀតដែលមានភារកិច្ច ឬមានឯកទេសលើវិស័យទាំងឡាយដែលបាននិយាយយោងនៅក្នុងអនុសញ្ញា ។

គណៈកម្មាធិការនេះគប្បីស្ថិតនៅក្រោមឱវាទរបស់ទេសរដ្ឋមន្ត្រី ឬមន្ត្រីជាន់ខ្ពស់ដែលទទួលខុសត្រូវក្នុងវិស័យសេវាកម្មជាតិ ដែលទាក់ទិនជាពិសេសទៅនឹងការងាររក្សាការពារសម្បត្តិវប្បធម៌ ។ តួនាទីសំខាន់ៗរបស់គណៈកម្មាធិការនេះគឺ:

ក) ផ្តល់យោបល់ជូនរដ្ឋាភិបាលអំពីបណ្តាវិធានការចាំបាច់សំរាប់ការអនុវត្តអនុសញ្ញា លើវិស័យច្បាប់ បច្ចេកទេស ឬយោធា ទាំងក្នុងពេលដែលប្រទេសជាតិមានសន្តិភាព និងទាំងក្នុងពេលមានសង្គ្រាម ។

ខ) ផ្តល់ជូនរដ្ឋាភិបាល នៅគ្រាមានកើតវិវាទប្រដាប់អាវុធ ឬនៅពេលដែលអធិករណ៍ហៀបនឹងផ្ទុះឡើង នូវទស្សនៈក្នុងការធានាថា សម្បត្តិវប្បធម៌ដែលស្ថិតនៅក្នុងដែនដីរបស់ប្រទេសខ្លួន ឬនៅក្នុងដែនដីរបស់ប្រទេសដទៃទៀត ត្រូវបានទទួលស្គាល់ គោរព និងការពារ ពីសំណាក់កងកំលាំងប្រដាប់អាវុធរបស់ប្រទេសខ្លួន ស្របទៅតាមមាត្រាបញ្ញត្តិទាំងឡាយរបស់អនុសញ្ញា ។

គ) រៀបចំចាត់ចែង ដោយព្រមព្រៀងជាមួយរដ្ឋាភិបាលរបស់ខ្លួន អោយមានសម្ព័ន្ធភាព និងសហប្រតិបត្តិការជាមួយគណៈកម្មាធិការជាតិស្រដៀងគ្នានេះដទៃទៀត និងជាមួយអាជ្ញាធរអន្តរជាតិមានសមត្ថកិច្ចណាមួយ ។

*សេចក្តីសំរេចទី៣:*

សន្និសីទសំដែងនូវសេចក្តីសង្ឃឹមថា លោកអគ្គនាយកអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ នឹងកោះប្រជុំប្រទេសចុះកិច្ចសន្យាទាំងអស់ អោយបានឆាប់តាមដែលអាចធ្វើទៅបានបន្ទាប់ពីអនុសញ្ញាស្តីពីការការពារសម្បត្តិវប្បធម៌ក្នុងគ្រាមានជំលោះប្រដាប់អាវុធ បានចូលជាធរមានរួចហើយនោះ ។